ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ

កម្មវិធីទ្រទ្រង់ផ្នែកអប់រំបឋមសិក្សា
នៅកម្ពុជា របស់សហគមន៍អឺរ៉ុប

# ទស្សនាវដ្តី គ្រូបង្រៀន

លេខ ១



ខែ តុលា - វិច្ឆិកា - ធ្នូ ១៩៩៥

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១២៨ B. មហាវិថីព្រះនរោត្តម ( ភ្នំពេញ )

ទូរសព្ទ 015 918 124

# មាតិកាអត្ថបទ


១- អារម្ភកថា .........

២- ព្រះរាជសាររបស់ សម្តេចក្រុមព្រះ នរោត្តម រណប្ញទ្ធិ នាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ថ្លែងក្នុងឱកាសទិវាបវេសនកាលឆ្នាំ ១៩៩៥-៩៦

- អត្ថន័យរូបភាព

៣- សមាគមបុគ្គលិកសិក្សាខ្មែរ

- ប្រវត្តិសង្ខេបនៃ ស.ប.ស. ខ.
- ប្រវត្តិរូបសញ្ញាក្រសួងអប់រំ
- ការពិចារណាលើនិមិត្តរូបនៃរូបសញ្ញា

៤- ពតិមានរដ្ឋបាល

- សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ( ជំពូកទី១ ទី ២ និង ទី៣ )
- លិខិតណែនាំស្វ័យសិក្សាឯកសារបណ្តុះបណ្តាលពីចំងាយ ..........

៥- វប្បធម៌ទូទៅ - ការអប់រំ

- លើកកំពស់ស្មារតីស្រលាញ់មរតកបុព្វបុរសខ្មែរ
- សមាសភាគនៃការអប់រំ

៦- គរុកោសល្យ - ការគ្រប់គ្រង

- បញ្ហាសិស្សឈប់ច្រើន និងរៀនមិនចប់កម្មវិធី
- គោលបំនងនៃការបង្រៀនវិទ្យាសាស្ត្រអនុវត្តនៅបឋមសិក្សា
- គ្មានទេ ថ្នាក់ស្មើសាច់នោះ




## I - គណៈកម្មការតំរង់ទិស - អំណាន និងតាមដាន

1 - លោក យឹង់ ធី ប្រធាន

2 - លោក ស៊ិន ង្ហួនហេង សមាជិក

3 - លោក ណាត ប៊ុនរឿន សមាជិក

4 - លោក ធ សោ សមាជិក

5 - លោក ជា ជាតិ សមាជិក

6 - លោក ស៊ុង វ៉ាន់ថន សមាជិក

7 - លោកស្រី ហ្លួរ សិរី សមាជិក

8 - លោក សង់ មីសែលឡឺប៊ុច សមាជិក

9 - លោក សេរា រិទ្ធ សមាជិក

## II - គណៈកម្មការតែងអត្ថបទ

1 - លោក យឹង់ យ៉ាណូ

2 - លោក ឆយ យីហ៊ាំង

3 - លោក អ៊ិម កុច

4 - លោក កង ឌិម

5 - លោក ពត សុត

6 - លោក ផិន សុកហេង

7 - អ្នកស្រី ផាន់ សំអោ

8 - អ្នកស្រី អ៊ិច សារូ

9 - លោក សំអាន សាយ

10 - លោក ប្រាក់ ព្រុំ

11 - លោកអធិការបឋមសិក្សានៅគ្រប់ខេត្ត - ក្រុង
បណ្ដុះបណ្ដាលនៅមហាវិទ្យាល័យគរុកោសល្យ


ទស្សនាវដ្ដីនេះបោះពុម្ពដោយមានការរួមចំណែកជាបច្ចេកទេស និងហិរញ្ញវត្ថុ
ពី **កម្មវិធីទ្រទ្រង់ផ្នែកអប់រំបឋមសិក្សានៅកម្ពុជារបស់សហគមន៍អឺរ៉ុប**

Revue publiée avec le concours technique et financier
du Programme d'Appui au Secteur de l'Education Primaire
au Cambodge ( PASEC ) de l'Union Européenne.

# អារម្ភកថា

ជាងពីរទសវត្សរ៍នៃសង្គ្រាមរ៉ាំរ៉ៃ ‹‹ ទស្សនាវដ្ដីគ្រូបង្រៀន ›› បានឃ្លាតឆ្ងាយពីហត្ថា និងនេត្រារបស់លោកគ្រូ-អ្នកគ្រូ ជាទីគោរពរាប់អាន ។

ថ្ងៃនេះ ‹‹ ទស្សនាវដ្ដីគ្រូបង្រៀន ›› សូមបង្ហាញខ្លួនជាថ្មីឡើងវិញប្រកបដោយមនោសញ្ចេតនាទីករលើក និងស្វាគមន៍យ៉ាងកក់ក្ដៅចំពោះ លោកគ្រូ - អ្នកគ្រូ ហើយសូមប្រសិទ្ធិពរជូនលោកគ្រូ - អ្នកគ្រូ សូមប្រកបតែសេចក្ដីសុខចំរើនគ្រប់ប្រការ និងសំរេចបានជ័យជំនះគ្រប់ភារកិច្ច ។

កំនើតថ្មីនៃទស្សនាវដ្ដីគ្រូបង្រៀនបានប្រសូតឡើងវិញនេះ អាស្រ័យដោយការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការនាយកនៃសមាគមបុគ្គលិកសិក្សាខ្មែរ ។ ដំបូងយើងមានគោលបំនងបង្កើតត្រឹមតែព្រឹត្តិប័ត្រប្រចាំសមាគមតែប៉ុណ្ណោះ តែដោយមានសំនូមពរពីសមាជិកសមាជិការបស់សមាគមភាគច្រើនបានសុំបង្កើត ‹‹ ទស្សនាវដ្ដីគ្រូបង្រៀន ›› ឡើងវិញ ដើម្បីអោយមានជីវិតបន្តពីសម័យសង្គមរាស្ត្រនិយមមក យើងក៏បានសំរេចបង្កើត ‹‹ ទស្សនាវដ្ដីគ្រូបង្រៀន ›› នេះ ដោយសុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជននិងកីឡា និងពីក្រសួងពត៌មានរហូតទទួលបានការយល់ព្រម និងសំរេចជាស្ថាពរ ។ នេះគឺជាកំនើតថ្មីនៃ‹‹ ទស្សនាវដ្ដីគ្រូបង្រៀន ›› ដែលអស់លោក - លោកស្រី លោកគ្រូ - អ្នកគ្រូ កំពុងកាន់នៅដៃនេះ ។

ក្នុងការរៀបចំ ទស្សនាវដ្ដីអោយបានលេចរូបរាងនេះឡើង គណៈកម្មាធិការនាយកនៃសមាគមបុគ្គលិកសិក្សាខ្មែរ បានទំនាក់ទំនងជាមួយកម្មវិធីគ្រប់គ្រងផ្នែកបឋមសិក្សានៅកម្ពុជារបស់សហគមន៍អឺរ៉ុប ជាំសិច PASEC ដែលបានជួយជាថវិកាបោះពុម្ពចំនួន ៦០.០០០ ក្បាល រល់ត្រីមាសក្នុងឆ្នាំសិក្សា ១៩៩៥ - ៩៦ នេះ ។ នេះជាអំណោយផលមួយដ៏សំខាន់. ដែលអាចធ្វើអោយទស្សនាវដ្ដីយើងមានដំណើរការក្នុងដំណាក់កាលដំបូងដែលយើងពុំទាន់មានមូលដ្ឋានថវិកានៅឡើយ ។ ជាមួយនោះដែរ គណៈកម្មាធិការយើងបានប្រមែប្រមូលលោកគ្រូ - អ្នកគ្រូ ដែលមានបទពិសោធ ទោះបីចូលនិវត្តន៍ហើយក្ដីអោយមកជួយរៀបចំទាំងផ្នែករដ្ឋបាល និង បច្ចេកទេស ដើម្បីធ្វើយ៉ាងណាអោយទស្សនាវដ្ដីនេះចេញរួច ។

តាមឧត្ដមគតិ និងប្រពៃណីរបស់ខ្លួន ‹‹ ទស្សនាវដ្ដីគ្រូបង្រៀន ›› មានគោលបំនង ៖

- រឹតចំណងសាមគ្គីភាពក្នុងជួរគ្រូបង្រៀនយើងគ្រប់ក្របខ័ណ្ឌអោយកាន់តែយោគយល់គ្នា
- អោយលោកគ្រូ - អ្នកគ្រូ បានទទួលដំណឹងពីគ្នាទៅវិញទៅមក
- អោយលោកគ្រូ - អ្នកគ្រូ បានទទួលបទពិសោធន៍ និងចំណេះដឹងថ្មីៗ ល្អៗ រវាងគ្នានិងគ្នា ដើម្បីលើកកំពស់មុខវិជ្ជាជីវៈ និង គុណភាពអប់រំ
- លើកកិត្តិយស និង លើកកំពស់គុណធម៌ សីលធម៌ នៃមុខវិជ្ជាជីវៈគ្រូបង្រៀន

យើងខ្ញុំសង្ឃឹមថា ‹‹ ទស្សនាវដ្ដី ›› នឹងរួមចំណែកយ៉ាងសកម្ម ដល់ការលើកកំពស់សាមគ្គីភាព ការយោគយល់គ្នារវាងគ្រូបង្រៀន និងគ្រូបង្រៀនផងគ្នា និងដល់ការផ្ដល់ចំណេះដឹងទៅវិញទៅមក ។ ម្យ៉ាងទៀតទស្សនាវដ្ដី នឹងអាចក្លាយទៅជាមធ្យោបាយដ៏សំខាន់រួមចំណែកលើកកំពស់វិស័យអប់រំ ដែលកំពុងជួបប្រទះ នូវវិបត្តិធ្ងន់ធ្ងរ ពាក់ព័ន្ធនឹងកំសោយរបស់សិស្ស ដែលទាំងអស់នេះត្រូវធ្លាក់មកលើយើងទាំងអស់គ្នាជាគ្រូបង្រៀន ចាំបាច់យើងត្រូវតែរកវិធីដោះស្រាយអោយបានទាន់ពេលវេលា ។ បើពុំដូច្នោះទេ វិស័យអប់រំរបស់យើងនេះចេះតែដុនដាបទៅៗ ហើយប្រទេសជាតិ នឹងអាចឈានទៅដល់ក្ដីវិនាសក្នុងពេលណាមួយ ។

**គណៈកម្មាធិការកណ្ដាល**

# សម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ
## នាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា

# ព្រះរាជសារ

## របស់ សម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ថ្លែងក្នុងឱកាសទិវាបវេសនកាល ឆ្នាំ ១៩៩៥-៩៦

- ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ
- ព្រះអង្គម្ចាស់ សម្ដេច ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រីជាទីមេត្រី
- បងប្អូនរួមជាតិ លោកគ្រូ អ្នកគ្រូទាំងអស់ ជាទីគោរពស្នេហា
- ក្មួយៗ សិស្សានុសិស្ស និស្សិត ជាទីស្រលាញ់រាប់អានដ៏កក់ក្ដៅ

ក្នុងឱកាសបុណ្យទិវាបវេសនកាល ឆ្នាំ ១៩៩៥-៩៦ នេះ តាងព្រះបរមនាម ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទសម្ដេច **ព្រះនរោត្ដម សីហនុ វរ្ម័ន** សម្ដេចឪ សម្ដេចតា សម្ដេចតាទួត ព្រះបិតាសិក្សាធិការជាតិ ជាទីសក្ការៈ ព្រមទាំងតាងនាមរាជរដ្ឋាភិបាល និងក្នុងនាមសម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ និងក្នុងនាមខ្ញុំព្រះករុណា- ខ្ញុំផ្ទាល់ ខ្ញុំព្រះករុណា - ខ្ញុំសូមអបអរសាទរដោយក្ដីសោមនស្សរីករាយក្រៃលែង និងសូមសរសើរដោយស្មោះ ចំពោះការខិតខំប្រឹងប្រែងដ៏ខ្ពង់ខ្ពស់របស់បងប្អូនរួមជាតិទាំងមូល ជាពិសេសលោកគ្រូ អ្នកគ្រូ និងក្មួយៗសិស្សានុសិស្សក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំទិវាបវេសនកាលឆ្នាំនេះ ប្រកបដោយភាពមហោឡារិក និងមានខ្លឹមសារបំផុត ចាត់ទុកជាថ្ងៃបុណ្យដែលឪពុកម្ដាយទាំងអស់ ត្រូវបញ្ជូនកូនទៅសាលារៀន និងជាថ្ងៃបុណ្យរបស់ក្មួយៗទទួលនូវចំណេះដឹងថ្មីៗថែមទៀត ។

- ព្រះថេរានុត្ថេរៈ ជាទីសក្ការៈ
- ព្រះអង្គម្ចាស់ សម្ដេច ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី ជាទីគោរព
- បងប្អូនរួមជាតិ មន្ត្រីរាជការ លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងក្មួយៗទាំងអស់ជាទីមេត្រី

ឆ្លងកាត់ការលំបាកស្មុគស្មាញ នៃសង្គ្រាមរ៉ាំរ៉ៃក្នុងស្រុកជាង ២ ទសវត្សរ៍ និងបន្ទាប់ពីហេដ្ឋារចនាសម្ព័ន្ធគ្រប់

វិស័យ ជាពិសេសវិស័យអប់រំ សិក្សាធិការ វប្បធម៌ជាតិ និងប្រពៃណីថ្លៃថ្នូររបស់ជាតិ ត្រូវបានខូចខាតខ្ទេចខ្ទាំ និងសាបរលាបមក យើងបានខិតខំរៀបចំស្តារ និងកសាងឡើងវិញ ជាបណ្តើរៗ ក្នុងដំណើរទៅមុខ និងរីកចំរើនជាបន្តបន្ទាប់ ។

ក្នុងបណ្តាឆ្នាំកន្លងមក ពិសេសក្នុងពីរឆ្នាំកន្លងទៅនេះ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល និងដោយមានការចូលរួមពីសហគមន៍ជាតិ និងអន្តរជាតិ ប្រទេសជាតិយើងត្រូវបានស្តារ និងកសាងឡើងវិញ ប្រកបដោយសន្ទុះខ្លាំងក្លា និងរីកចំរើនគ្រប់វិស័យ ក្នុងនោះវិស័យអប់រំបានលេចធ្លោទាំងផ្នែកបរិមាណ និងគុណភាព ជាក់ស្តែង មកដល់ឆ្នាំសិក្សា ១៩៩៤-៩៥ នេះ ៖

**ផ្នែកឧត្តមសិក្សា:** យើងមានគ្រឹះស្ថានឧត្តមសិក្សា ចំនួន ៨ មានមុខវិជ្ជាជំនាញ ៣៣ សាលាមធ្យមសិក្សាបច្ចេកទេស ១៩ និងនិស្សិតសរុប ១៦.៣៥០ នាក់

**ផ្នែកមធ្យមសិក្សា:** មាន វិទ្យាល័យ ៩០ សិស្ស ៩៦.៣៧១ នាក់ អនុវិទ្យាល័យ ៣៤៨ សិស្ស ១៩.៦៧២ នាក់

**ផ្នែកបឋមសិក្សា:** មាន សាលា ៤.៨០៤ សិស្ស ១.៦៤៦.៩២១ នាក់

**ផ្នែកមត្តេយ្យសិក្សា:** មាន សាលា ២១០ សិស្ស ៥០.៩៥៣ នាក់

យើងមានមន្ត្រីរាជការ បុគ្គលិកសិក្សា សរុបចំនួន ៧៦.៥៣៦ នាក់ ដើម្បីដឹកនាំនិងគ្រប់គ្រងការងារទាំងឡាយខាងលើ ។

ក្នុងទិសដៅស្វែងរកគុណភាពអប់រំ និងក្នុងស្មារតីឯកភាពចូលរួមយ៉ាងខ្ជាប់ខ្ជួន ពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ពីលោកគ្រូ អ្នកគ្រូ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ជាមួយនឹងស្មារតីភ្ញាក់រលឹករបស់មាតាបិតា និងសិស្សានុសិស្ស ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើអោយសំរេចលទ្ធផល គួរអោយមោទនៈ គឺ ៖

- សិស្សប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ចំនួន ២.៥១៧ នាក់ ស្មើនឹង ១២,០៨ %
- សិស្សប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត១ ចំនួន ២២.៥៨៨ នាក់ ស្មើនឹង ៣២,៥៤ %
- សិស្សប្រលងជាប់សញ្ញាប័ត្របឋមសិក្សា ចំនួន ៨៥.២៥១ នាក់ ស្មើនឹង ៥៥,៤៣ %

## ក្មួយៗសិស្សានុសិស្ស និងនិស្សិតទាំងអស់ជាទីស្នេហា !

ឆ្នាំសិក្សាថ្មីចូលមកដល់ហើយ ចូរក្មួយៗត្រៀមខ្លួនអោយបានល្អ ដើម្បីត្រងត្រាប់ស្តាប់ការណែនាំ អប់រំ និងបង្រៀនពីលោកគ្រូ អ្នកគ្រូ និងខិតខំគោរពវិន័យ បទបញ្ជាផ្ទៃក្នុងរបស់សាលារៀន អប់រំខ្លួនអោយក្លាយទៅជា កូនល្អ សិស្សល្អ និងមិត្តល្អ ជាយុវជនសកម្មប្រយុទ្ធក្នុងការរៀនសូត្រ និងសកម្មភាពផ្សេងៗទៀត ដែលបានកំនត់ក្នុងកម្មវិធីសិក្សាសំដៅអោយមានការរីកចំរើនពេញលេញ ខាងកាយសម្បទា បញ្ញាសម្បទា សីលធម៌សម្បទា វិជ្ជាជីវៈសម្បទា ព្រមទាំងមានមនសិការជាតិខ្ពង់ខ្ពស់ប្រាកដ ដូចសម័យសង្គមរាស្ត្រនិយម ដ៏រុងរឿងនៃសម្តេចឪ សម្តេចតា សម្តេចតាទួត ជាទីសក្ការៈនៃយើង ។ ចង់បានដូចនេះ ជាបូងបំផុត ក្មួយៗត្រូវតែភ្ញាក់រលឹក ក្នុងការសិក្សា បណ្តុះពីកវប្បធម៌ វិទ្យាសាស្ត្របច្ចេកទេស និងគុណធម៌ រស់នៅហាក់ពត់កាយិយាបថអោយបានសមរម្យ និងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគ្រប់សកម្មភាពរបស់សាលា ។ ទន្ទឹមនឹងនេះ ក្មួយៗត្រូវកំណត់អោយបានច្បាស់ថា ព្រះរាជាណាចក្រកម្ពុជាយើង កំពុងបង្រួបបង្រួមប្រមូលកំលាំងសាមគ្គី ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ ។ ដូចនេះ កត្តាសំខាន់ និងភារកិច្ចចំបងរបស់ក្មួយៗ គឺខិតខំរៀនសូត្រប្រកបដោយគុណភាពពិសេសត្រូវរៀនអោយបានចេះនូវឯកទេស វិជ្ជាជីវៈណាមួយយ៉ាងច្បាស់លាស់ ដើម្បីចូលរួមចំណែក កសាងកម្ពុជាថ្មីអោយ

រីកចំរើនយ៉ាងឆាប់រហ័ស ។

លោកគ្រូ អ្នកគ្រូ លោកសាស្ត្រាចារ្យជាទីគោរពស្នេហា !

ស្នាដៃ និងសមត្ថភាពការងារ តួបផ្សំ និងមនសិការវិជ្ជាជីវៈ ដែលលោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូគ្រប់កំរិតសិក្សា បានបង្ហាញអោយឃើញកន្លងមក ជាមោទនភាពដ៏ធំធេងរបស់វិស័យអប់រំ ហើយក៏ជាការរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ ដោយកត្តិយសថ្លៃថ្នូរជាទីបំផុត ។

ជាថ្មីម្តងទៀត ខ្ញុំសូមលោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បន្តភារកិច្ចដ៏ឧត្តុង្គឧត្តមនេះ ដោយសំរួចឆន្ទៈអនុវត្តការងារអោយកាន់តែខ្លាំងក្លាថែមទៀត ពង្រឹងសាមគ្គីផ្ទៃក្នុងអោយស៊ុសង្វាក់គ្នា និងទូលំទូលាយ ឯកភាពចូលរួមយ៉ាងសកម្មក្នុងកិច្ចអភិវឌ្ឍន៍ព្រះរាជណាចក្រកម្ពុជាយើង ។ សំខាន់ជាងនេះ អស់លោក-លោកស្រី គឺជាអ្នកធ្វើអោយសំរេចនូវរាល់ទិសដៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ ជាចំបង យើងធ្វើអ្វីៗសព្វយ៉ាង ដើម្បីសិស្សានុសិស្សជាទីស្រលាញ់របស់យើង ពោលគឺបន្តលើកគុណភាពអប់រំ និងបង្រៀន ពិសេសនៅបឋមសិក្សា និងជំរុញការអប់រំពលកម្មពហុបច្ចេកទេស និងតំរង់ទិសវិជ្ជាជីវៈនៅតាមសាលារៀនចំណេះទូទៅ ដើម្បីឆ្លើយតបនឹងតំរូវការនៃប្រទេសជាតិបច្ចុប្បន្ន ។

- ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីសក្ការៈ
- បងប្អូនជនរួមជាតិ ជាទីគោរពស្នេហា

ខ្ញុំព្រះករុណា-ខ្ញុំ មានបីតិសោមនស្សរីករាយយ៉ាងខ្លាំង ដោយបានឃើញការចូលរួមចំណែកយ៉ាងសកម្មរបស់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនរួមជាតិទាំងអស់ក្នុងការងារលើកស្ទួយវិស័យអប់រំយើង ។ សូមព្រះអង្គ និងបងប្អូនជួយឧបត្ថម្ភបន្តទៅទៀត ក្នុងការកសាងអាគារសិក្សា និងកសាងមូលដ្ឋានសំភារៈនានា ក្នុងកាលៈទេសៈ ដែលរដ្ឋយើងពុំទាន់មានលទ្ធភាពវិនិយោគទុនគ្រប់គ្រាន់ ដល់វិស័យអប់រំ ។ ។

ទន្ទឹមនឹងការជួយឧបត្ថម្ភខាងផ្នែកសំភារៈ ខ្ញុំសូមអោយបងប្អូនទាំងអស់ ជួយដាស់តឿនក្រើនរំលឹកបញ្ជូនកូនចៅអោយទៅរៀនគ្រប់ៗគ្នា និងព្យាយាមរៀនសូត្រ បង្កលក្ខណៈអោយកូនចៅ មានពេលវេលារៀនសូត្រ និងធ្វើតំរូវល្អដល់កូនចៅ លើរាល់ការងារ និងជីវភាពរស់នៅប្រចាំថ្ងៃ ដើម្បីរួមចំណែកជួយសាលាក្នុងការងារអប់រំ តាមទិសស្លោក « **មាតាបិតាសហការជិតស្និទជាមួយសាលារៀន អប់រំកូនអោយចំណេះដឹង និងសីលធម៌ល្អ ›› ‹‹ អប់រំកូនអោយមានចំណេះដឹងល្អ និងសីលធម៌ថ្លៃថ្នូរ គឺមាតាបិតាមានតួនាទីជាអ្នកទី១ គ្រូបង្រៀនជាអ្នកទី២** ›› ។

ជាសំខាន់ ចាប់ពីឆ្នាំសិក្សានេះតទៅ សូមបងប្អូនមាតាបិតា អាណាព្យាបាល និងសិស្សានុសិស្សកំណត់ថា ទិវាបវេសនកាលឆ្នាំសិក្សា គឺជាថ្ងៃបុណ្យរបស់កូនចៅយើង ជាទិវាដ៏ឧត្តម ដែលបងប្អូនបានចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ ។

ឆ្លៀតក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ ខ្ញុំព្រះករុណា-ខ្ញុំ សូមអំពាវនាវដល់អាជ្ញាធរគ្រប់ជាន់ថ្នាក់ ព្រះថេរានុត្ថេរៈ បងប្អូនប្រជាពលរដ្ឋក្នុង និងក្រៅប្រទេស អង្គការអន្តរជាតិនានា សប្បុរសជនទាំងឡាយ សូមចូលរួមជួយឧបត្ថម្ភវិស័យអប់រំកាន់តែខ្លាំងក្លាថែមទៀត ទាំងស្មារតីនិងសំភារៈ ដើម្បីអោយមានការរីកចំរើនគ្រប់វិស័យនៃព្រះរាជាណាចក្រកម្ពុជា សំដៅអោយមានការរីកចំរើនឆាប់រហ័ស តាមការវិវត្តន៍នៃសកលលោក ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា-ខ្ញុំ សូមសំដែងនូវសេចក្តីត្រេកអរជាពន្លឹក និងថ្លែងនូវកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះសមានចិត្ត និងកាយវិការដ៏ល្អប្រពៃ ចូលរួមអបអរសាទរទិវាបវេសនកាលរបស់កូន ក្មួយ ចៅ របស់យើងនៅគ្រប់ភូមិ ឃុំ ស្រុក ខេត្ត-ក្រុង ពីសំណាក់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជនរួមជាតិក្នុងនិងក្រៅប្រទេស អង្គការអន្តរជាតិនានានៃបណ្តាប្រទេសជាមិត្តទាំងអស់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ក្មួយៗសិស្សានុសិស្ស និស្សិត ដែលបានរួមចំណែកដ៏ស្មោះ

ស្ម័គ្រ ក្នុងការកសាងវិស័យអប់រំនៃព្រះរាជាណាចក្រកម្ពុជា អោយមានប្រសិទ្ធិភាព និងសមត្ថភាពល្អប្រសើរ ។ សូមព្រះតេជគុណ ព្រះអង្គម្ចាស់ សម្តេច ឯកឧត្តម លោកជំទាវ អស់លោក-លោកស្រី លោកយាយ-លោកតា លោកម៉ីង លោកពូ បងប្អូនប្រុសស្រី បានសមប្រកបដោយសេចក្តីសុខចំរើន សំបូរសប្បាយ និងជាពិសេស ក្មួយៗសិស្សានុសិស្ស សូមសំរេចនូវសុខភាពល្អ ថាមពលខ្លាំងក្លា បញ្ញាឈ្លាសវៃ មានស្មារតីចងចាំពូកែ ក្នុងការសិក្សា ហើយសូមទទួលបាននូវព្រះពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណះ សុខះ ពលះ និងបដិភាណះ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរព្រះគុណ និង អរគុណ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ១៩៩៥

**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា**



ឯកឧត្តម តុល ឡោះ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អានព្រះរាជសាររបស់សម្តេចក្រុមព្រះ ក្នុងឱកាសបើកបវេសនកាលនៅសាលាបឋមសិក្សាព្រះនរោត្តមរាជធានីភ្នំពេញ ។

# ការបកស្រាយន័យរូបភាព នៅក្របសៀវភៅ

១- នៅផ្ទៃមុខ អ្នកអប់រំពីររូប ប្រុសស្រី កំពុងប្រគល់សៀវភៅទៅអោយយុវជនពីររូបប្រុស ស្រី ដូចគ្នា ។

រូបភាពមានអត្ថន័យថា អ្នកអប់រំទាំងពីររូបតំណាងជំនាន់មនុស្សវ័យកណ្តាល កំពុងតែធ្វើការផ្ទេរចំណេះដឹង ទៅអោយយុវជនជំនាន់ក្រោយ ។ ទង្វើនេះ គឺជាកិច្ចក្រមមួយនៃធម៌ទ្រទ្រង់មនុស្សជាតិទាំងប្រាំ ដែលមនុស្សគ្រប់រូបត្រូវតែអនុវត្តអោយបានមុនធ្វើមរណកាល ។

២- នៅផ្ទៃក្រោយ គឺព្រះហរិហរៈ ដែលជាព្រះអាទិទេពផ្សំរវាងព្រះវិស្ណុ និងព្រះសិវៈ ( ប្រាសាទអណ្តែត ស.វ.ទី៧ ) នៅក្នុងខេត្តតាកែវ

- ចំហៀងឆ្វេង គឺព្រះហរិ រឺព្រះវិស្ណុ រឺព្រះនរាយណ៍ ។

- ចំហៀងស្តាំ គឺព្រះហរៈ រឺព្រះសិវៈ រឺព្រះឥសូរ ។

បដិមានេះ ជានិមិត្តរូបនៃការផ្សះផ្សាអោយបានឯកភាពគ្នា រវាងអ្នកគោរពបូជាព្រះវិស្ណុនិងអ្នកគោរពបូជាព្រះឥសូរ ដែលបែកបាក់គ្នាព្រោះតែជំនឿខុសគ្នា ។

**************

**ក.ន.** ប្រជាពលរដ្ឋខ្មែរ គួរកំទត់វប្បធម៌ដែលជាព្រលឹងខ្មែរ ជាគាវរូបសំរាប់ផ្សះផ្សា និងបង្រួបបង្រួមជាតិ ។ ការគោរពបូជា ជាសក្ខីភាពតែមួយគត់នៃឯកភាពជាតិ ។

**ដោយ លោក យ៉ង់ ធី**



# សមាគមបុគ្គលិកសិក្សាខ្មែរ

## ប្រវត្តិសង្ខេប
## នៃ
## សមាគមបុគ្គលិកសិក្សាខ្មែរ

លោកគ្រូ - អ្នកគ្រូវ័យក្មេងដែលត្រូវបានចូលបំរើក្រសួងអប់រំក្រោយឆ្នាំ ១៩៧៩ ពិតជាមិនទាន់បានស្គាល់ និងពុំទាន់បានលឺថាតើអ្វីទៅសមាគមបុគ្គលិកសិក្សាខ្មែរ ។ នេះជាការពិតព្រោះសមាគមយើងដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩៤៧ នោះត្រូវបានរលំរលាយនៅថ្ងៃទី ១៧ មេសា ១៩៧៥ ។

ថ្ងៃនោះជាថ្ងៃអាណោចអាធ័មនៃការបើកទំព័រប្រវត្តិសាស្ត្រមួយដ៏ខ្មៅងងឹត ដែលគ្រូបង្រៀនយើង ក៏ដូចជាប្រជាពលរដ្ឋទូទាំងប្រទេស បានធ្លាក់ចូលទៅក្នុងក្រញាំបិសាចនៃរបបឃោរឃៅព្រៃផ្សៃមួយដែលមនុស្សលោកមិនដែលបានស្គាល់ ។

ថ្ងៃទី ០៣ កញ្ញា ១៩៩៤ សមាគមបុគ្គលិកសិក្សាខ្មែរយើងបានឃើញពន្លឺថ្ងៃឡើងវិញ ។ មហាសន្និបាតនៃតំណាងបុគ្គលិកសិក្សាខ្មែរបានចាប់ដំណើរទៅដោយមានអ្នកតំណាងមកពីក្រសួងអប់រំ ពីមន្ទីរអប់រំខេត្ត - ក្រុងចំនួន ១០១ចូលរួម ។ មហាសន្និបាតនេះបានប្រព្រឹត្តទៅនៅវិទ្យាល័យព្រះស៊ីសុវត្ថិ បានអនុម័តលក្ខន្តិកៈកែប្រែឡើងវិញ និងបានបោះឆ្នោតរើសគណៈកម្មាធិការកណ្ដាលមួយទទួលភារៈរៀបចំសមាគមអោយមានសកម្មភាពដើម្បីសំរេចគោលដៅកំនត់ ។ ខាងក្រោមនេះជាប្រវត្តិសង្ខេបរបស់សមាគមបុគ្គលិកសិក្សាខ្មែរ ៖

- ពីឆ្នាំ ១៩៤៧ ដល់ឆ្នាំ ១៩៥៨ សមាគមបុគ្គលិកសិក្សាខ្មែរយើងមានឈ្មោះថា « គរុសង្គហៈ ›› មានគោលបំណងបង្កើតអោយមានចំណងមិត្តភាព និងការឧបត្ថម្ភគ្នាទៅវិញទៅមក ព្រមទាំងរឹតចំណងនោះអោយកាន់តែរឹងមាំឡើង ។ លក្ខន្តិកៈសមាគម ត្រូវបានសាលាវិនិច្ឆ័យទទួលស្គាល់នៅថ្ងៃ ១៨ មិនា ១៩៤៩ ។ មហាសន្និបាតថ្ងៃទី ២៨ មេសា ១៩៤៩ បានជ្រើសរើសគណៈកម្មាធិការនាយកមួយជាស្ថាពរ ។

- រវាងឆ្នាំ ១៩៤៩ និងឆ្នាំ ១៩៥៦ សកម្មភាពសមាគមមានតែការឧបត្ថម្ភជាអំណោយនៅឱកាសមានអាសន្ន និងចាំបាច់ ។

- នៅថ្ងៃ ៤ សីហា ១៩៥៧ មានមហាសន្និបាតមួយមានគ្រូចំនួន ៧០០ នាក់ បានមកប្រជុំនៅវិទ្យាល័យស៊ីសុវត្ថិ ដើម្បីជ្រើសរើសគណៈកម្មាធិការមួយថ្មីទៀត ដែលមានភារៈរៀបចំកែលំអលក្ខន្តិកៈជាថ្មីឡើងវិញ ។

- មហាសន្និបាតឆ្នាំ ១៩៥៨ នៅសាលាព្រះជ័យចេស្ដា ដោយមានគ្រូប្រហែល ៨០០ នាក់

មកប្រជុំ បានសំរេចកែប្រែលក្ខន្តិកៈតាមសេចក្ដីស្នើរបស់គណៈកម្មាធិការកណ្ដាល ។ ចាប់ពីឆ្នាំនោះមក គរុសង្គហៈ ( Mutuelle des enseignants ) ត្រូវបានប្រែឈ្មោះជាសមាគមបុគ្គលិកសិក្សាខ្មែរ( ស.ប.ស.ខ ) (Association du corps enseignant Khmer << A. C. E. K >> ) ។ ប្រាំបួនឆ្នាំក្រោយមក គំនិតថ្មីមួយបានផុសឡើង គឺគំនិតបង្កើតបេឡាគរុមរណបត្ថម្ភ នៅពេលមាន :

១- អនិច្ចកម្មសមាជិក និង គូស្រករ

២ - ការបញ្ឈប់ដោយហេតុសុខភាព : របេង ឆ្កួត ខ្វាក់ ខ្វិន ជាដើម ។

- មហាសន្និបាតថ្ងៃទី ១ មករា ១៩៦៧ បានសំរេចបង្កើតបេឡាគរុមរណបត្ថម្ភ ហើយធ្វើបទបញ្ញាភ្ជាប់នឹងលក្ខន្តិកៈដើម ។ ក្នុងន័យនេះហើយ A. C. E. K រឺ ស.ប.ស.ខ ត្រូវបានទទួលឈ្មោះមួយថ្មីទៀត ហៅថា << A. M. C. E. K >> គឺជាអក្សរសរសេរកាត់ចេញពី Association Mutualiste du Corps Enseignant Khmer ។

ចាប់ពីឆ្នាំនោះមក សមាគមមានសកម្មភាពឡើងវិញគួរជាទីកត់សំគាល់ ។ សមិទ្ធិផលដ៏ច្រើនបានលេចឡើង មានជាអាទិ ការសាងសង់បដិសណ្ឋារមណ្ឌលនៅស្ទើរតែគ្រប់ខេត្តក្រុង ដើម្បីអោយសមាជិក ‹‹ ស.ប.ស.ខ ›› ទាំងអស់អាចស្នាក់អាស្រ័យនៅ នៅពេលមានដំណើរឆ្លងកាត់ ។

នៅភ្នំពេញ ទីស្នាក់ការនៃគណៈកម្មាធិការកណ្ដាលលេខ ៥ ផ្លូវ ឧកញ៉ាម៉ែន ត្រូវបានចាត់ចែងជាផ្ទះសំណាក់ផងដែរ ដែលមានរៀបចំអោយមានបណ្ណាល័យ បន្ទប់អាន បន្ទប់សន្និសីទ និងកន្លែងលេងកូនឃ្លីលើតុ ល្បែងចត្រង្គ ។ សមាគមបានខិតខំអស់ពីកំលាំងកាយ - ចិត្ត ធ្វើការដើម្បីផលប្រយោជន៍សមាជិកសមាគម ។ នៅគ្រប់ទីកន្លែង គេសង្កេតឃើញថាគ្រូយើងមានសាមគ្គីភាព និងមានការជួយគ្នាទៅវិញទៅមកយ៉ាងល្អប្រសើរ រៀងដរាបរហូតដល់ឆ្នាំ១៩៧៥ ។

ដូចនេះការរស់ឡើងវិញនៃសមាគមបុគ្គលិកសិក្សាខ្មែរនៅឆ្នាំ ១៩៩៤ នាពេលនេះជាការបំពេញសំណូមពររបស់លោកគ្រូ - អ្នកគ្រូគ្រប់ជាន់ថ្នាក់នៃសង្គមគ្រូសាររយើងទូទាំងប្រទេស ។

សូមសមាគមបុគ្គលិកសិក្សាខ្មែរបំពេញបេសកកម្មដ៏ថ្លៃថ្លារបស់ខ្លួនបានជោគជ័យទៅអនាគត ។

សូមកុំអោយមានឧបសគ្គអ្វីមករារាំងឡើយ ។

**ជយោ ! សមាគមបុគ្គលិកសិក្សាខ្មែរ**

**ដោយ លោក យ៉ទ់ ឌី**

# ប្រវត្តិសញ្ញាក្រសួងអប់រំ

សញ្ញាក្រសួងអប់រំ គួរតែមានការពន្យល់បំភ្លឺអោយបានជ្រួតជ្រាបដល់លោកគ្រូ - អ្នកគ្រូទូទាំងប្រទេស ព្រោះនិមិត្តរូបរបស់សញ្ញាមានន័យទូលំទូលាយគួរជាទីមោទនៈចំពោះតួនាទីអ្នកអប់រំ ។

សមាគមបុគ្គលិកសិក្សាខ្មែរ តាំងពីកកើតឡើងដំបូង បានយកសញ្ញាក្រសួងអប់រំធ្វើជាសញ្ញារបស់ខ្លួន ។ គេតែងតែឆ្ងល់ថាហេតុអ្វីបានជាសមាគម មិនមានរូបសញ្ញាផ្ទាល់ខ្លួន ។ចំពោះសំនួរនេះ ខ្ញុំនឹងបំភ្លឺជូនជ្រាបដូចខាងក្រោម ។

ដូចអស់លោកបានជ្រាបហើយថា គ្រប់ទីស្ដីការរដ្ឋមន្ត្រីក្រសួងនានារបស់រាជរដ្ឋាភិបាលតែងតែមានសញ្ញាសំគាល់ប្លែកៗគ្នាទៅតាមមុខងាររបស់ក្រសួងនីមួយៗ ។

ក្រសួងអប់រំមានសញ្ញាសំគាល់ផ្ទាល់ខ្លួនមួយតាំងពីឆ្នាំ ១៩៤៨ ។ ប៉ុន្តែ និមិត្តរូបខ្លះបានផ្លាស់ប្តូរក្នុងរយៈរបបនយោបាយទាំងប៉ុន្មានមក ។

ដូចនេះ ជាភារកិច្ចយើងខ្ញុំគណៈកម្មាធិការកណ្តាលនៃសមាគមបុគ្គលិកសិក្សាខ្មែរ យើងខ្ញុំសូមបង្ហាញជូនចំពោះលោកគ្រូ - អ្នកគ្រូ នូវសញ្ញាក្រសួងអប់រំ ដើម្បីអោយបានយល់ន័យនៃសញ្ញានេះ ។

សញ្ញានេះបានឧប្បត្តិកឡើងដោយព្រះរាជក្រឹត្យលេខ ១៣ ស.ន ចុះថ្ងៃទី ២០-១-១៩៤៨ ដូចឯកសារជូនភ្ជាប់ ហើយត្រូវបានប្រើប្រាស់នៅគ្រប់ពិធីបុណ្យរបស់ក្រសួង ។ម្យ៉ាងទៀតរូបសញ្ញានេះត្រូវបានទុកជាលក្ខណសញ្ញា (Insigne) នៃមន្ត្រីអប់រំដែលមានបណ្ដាសក្តិ ពី ៦ហ្វីពាន់ ដល់ ៩ហ្វីពាន់ ។ គេពាក់សញ្ញានេះនៅក្នុងពិធីបុណ្យធំៗ ក្នុងព្រះរាជវាំង ដោយមានសំលៀកបំពាក់ជាផ្លូវការ ។

រូបសញ្ញាមានទំរង់ខុសៗគ្នាបន្តិចតាំងពីឆ្នាំកំនើត (១៩៤៨) រហូតដល់ថ្ងៃ ១៧ មេសា ១៩៧៥ ដែលជាថ្ងៃបំភ្លេចមិនបានចំពោះប្រជាពលរដ្ឋកម្ពុជាទាំងមូល ។ ខាងក្រោមនេះ គឺជារូបសញ្ញាដែលធ្លាប់បានឃើញហូរហែមកពីឆ្នាំ ១៩៤៨ ដល់ឆ្នាំ ១៩៧៥ ។





ខាងក្រោមនេះ គឺជាព្រះរាជក្រឹត្យលេខ ១៣ ន.ស. ចុះថ្ងៃទី ២០ មករា ១៩៤៨

KRET n° 13-NS du 20 Janvier 1948

**ARTICLE 1er. -** Il est créé pour les Mandarins de l'Enseignement Primaire ( Inspecteurs, Professeurs, Instituteurs et Instituteurs auxiliaires ) un insigne distinctif dont le croquis est annexé au présent Kret.

**ARTICLE 2. -** L'insigne est un flambeau de 60 m / m de hauteur portant à 10 m / m de sa base un cercle bombé et brillant de 16 m / m de diamètre, surmonté de deux coupes en forme de fleur de lotus à trois pétales : la grande coupe de 6 m / m de hauteur et 12 m / m de largeur est posée au sommet du cercle ; la petite ayant 12 m / m de hauteur et 10 m / m de largeur supporte une flamme de 13 m / , de hauteur.

Le flambeau est orné de chaque côté d'un motif décoratif national dit << Phnhi-Tès >> en forme de couronne de 47 m / m de hauteur et 45 m / m de largeur. Les bases du << Phnhi >> sont nouées à 5 m / m de la base du flambeau; leurs sommets touchent le bord de la petite coupe.

**ARTICLE 3. -** L'insigne est :

1° en argent sur fond bleu à rayures blanches et rouges pour les Mandarins de l'Enseignement ayant un rang comportant 6 et 7 pâns de dignité;

2° en métal doré sur même fond pour ceux ayant 8 et 9 pâns de dignité.

**ARTICLE 4. -** L'insigne se porte sur le côté droit à la hauteur de la poche supérieure.

**ARTICLE 5. -** LA démission, le licenciement ou la révocation entraînent d'office le retrait du port de l'insigne aux intéressés.

**ARTICLE 6. -** Le port illégal de cet insigne est puni des peines prévues par la Loi.

**ARTICLE 7. -** La confection de l'insigne est à la charge des intéressés.

**ARTICLE 8. -** La tenue officielle des Mandarins de l'Enseignement est la suivante :

a) - Tenue blanche, cravate noire, souliers noirs;

b) - Casque blanc.

**ARTICLE 9. -** La tenue blanche doit être portée au cours des cérémonies officielles en dehors du Palais Royal.

Dans la salle du trône et dans les pagodes, la tenue blanche est remplacée par la tenue traditionnelle qui se compose d'un Sampot et d'un dolman.

**ARTICLE 10. -**Le Ministre de l'Education Nationale, le Ministre de l'Intérieur, le Ministre de la Justice et le Sécrétaire Général du Gouvernement sont chargés, chacun en ce qui le concerne, de l'exécution du présent Kret

CROQUIS
de l'insigne pour les Mandarins de l'Enseignement Primaire au Cambodge



Vu pour être annexé
au Kret n° 13-NS du 20 Janvier 1948
Sa Majesté le Roi du Cambodge,
Signé : N. SIHANOUK.

Vu :
Phnom-Penh, Le 16 Janvier 1948
Le Commissaire de la République
Française au Cambodge,
Signé : L. PIGNON.

ចាប់ពីថ្ងៃ ៧-១-៧៩ វិចិត្រករបានគូររូបសញ្ញាក្រសួងមួយថ្មីទៀតដែលត្រូវបានប្រើរហូតមកដល់ឆ្នាំ ១៩៩៣



នៅថ្ងៃទី ៣០-១២-៩៣ ក្រសួងអប់រំ យុវជន និងកីឡា បានស្នើសុំសេចក្ដីអនុញ្ញាតប្រើប្រាស់រូបសញ្ញាចាស់ឡើងវិញ គឺរូបសញ្ញាដែលមានមកតាំងពីឆ្នាំ ១៩៤៨ ។តែវិចិត្រករគូរមិនដូចរូបសញ្ញាចាស់ ដូចបង្ហាញខាងលើនោះទេ ។



# ការពិចារណាលើនិមិត្តរូបនៃសញ្ញាក្រសួងអប់រំ

ព្រះរាជក្រឹត្យលេខ១៣ ន.ស. ចុះថ្ងៃទី ២០-១-៤៨ បានកំនត់ក្នុងមាត្រាទី២នូវលក្ខណៈនៃរូបសញ្ញាដូចតទៅ :

១ - លក្ខណៈសញ្ញា ( insingne ) គឺប្រទីបដែលមានកង រឺ ថាសមួយរាងជើង ភ្ជិ ភ្ជាប់នៅប្រវែង ១ ស.ម. ពីជើងប្រទីប ។

កងនេះត្រូវបានដាក់បន្ថែតពីលើនូវពានពីរ រាងផ្កាឈូកមានត្របកបី ( trois pétales ) ។

២ - ប្រទីបលំអដោយភ្ញីទេស មានរាងជាកំរងព័ទ្ធជុំវិញ ។ គល់ភ្ញីទេសចងនៅជើងប្រទីប ហើយចុងប៉ះតែមពានតូចខាងលើ ។

ព្រះរាជក្រិត្យបានពណ៌នាពីលក្ខណនៃរូបសញ្ញា តែមិនបានអោយយើងទាំងអស់គ្នាជាអ្នកអប់រំបានយល់ដឹងពីនិមិត្តរូបនៃសញ្ញានេះឡើយ ។ យើងសួរថា ហេតុអ្វីបានជាអ្នកមានគំនិតផ្តួចផ្តើមមានទស្សនទានកសាងលក្ខណសញ្ញាដូចនេះ ? តើរូបនីមួយៗ មានអត្ថន័យដូចម្តេច ? ដូចជា ភ្ញីទេស កង រឺ ថាស ពានតូច - ធំ ផ្កាឈូកមានត្របកបីរីក អណ្តាតភ្លើង និងកាំរស្មីនៃពន្លឺភ្លើងជះមកលើភ្ញីទេស ។

ចំពោះការចង់ដឹង ចង់យល់ពីនិមិត្តរូបនៃរូបសញ្ញាក្រសួងអប់រំ ខ្ញុំសូមសាកល្បងពិចារណាតាមការយល់ដឹងរបស់ខ្ញុំផ្ទាល់ ។ ខ្ញុំសូមលោកគ្រូ - អ្នកគ្រូមេត្តាផ្តល់មតិយោបល់បន្ថែមដើម្បីប្រមូលផ្តុំចងក្រងទុកចែកជូនអង្គបុគ្គលិកសិក្សាទុកជាវត្ថុមួយនាំអោយនឹកឃើញនូវតួនាទីរបស់ខ្លួន ។

តាមការស្រាវជ្រាវ ភ្ញីទេស គឺក្បាច់ភ្ញីដែលធ្វើជារូបដើម ទង ស្លឹក ផ្កា ផ្លែ ( វចនានុក្រមខ្មែរ ) ។ ដូចនេះខ្ញុំសន្និដ្ឋានថា ភ្ញីទេស ជាដើមឈើកំពុងរីកលូតលាស់ មានស្លឹកខៀវខ្ចី មានផ្កា មានផ្លែ ។ វាជានិមិត្តរូបនៃយុវវ័យកំពុងធំធាត់ និងប្រជាពលរដ្ឋទូទាំងប្រទេស ។ ភ្ញីទេសទាំងពីរទងបែកចេញពីប្រភពតែមួយ ។ បានសេចក្តីថា មានឫសគល់តែមួយ ។ រីឯកង រឺ ថាស ម្តេចក៏មានទីតាំងនៅទីនេះ ? គួរអោយឆ្ងល់ ។ តាមមតិខ្ញុំវាជានិមិត្តរូបនៃចំនេះវិជ្ជាទូទៅដែលបុព្វបុរសលើពិភពលោកតំកល់ទុកជាទ្រព្យសម្បត្តិរួម ។ ជាឃ្លាំងក្បួនច្បាប់ និងវិទ្យាសាស្ត្រដែលសន្សំបានកន្លងមកហើយ ។ ផ្អែកលើសាសនាព្រះពុទ្ធ ចក្រ រឺ កង ជានិមិត្តរូបនៃធម៌ដែលព្រះពុទ្ធបានត្រាស់ដឹង ។

ក្រោយពីបានត្រាស់ដឹងបាន ៥៩ ថ្ងៃ ព្រះអង្គទ្រង់យាងទៅក្រុងពារាណសី (BENARES) ក្នុងព្រះបំណងផ្សព្វផ្សាយធម៌ដែលព្រះអង្គបានត្រាស់ដឹង រីអោយធម្មចក្ររបស់ព្រះអង្គបានចាប់វិលពីថ្ងៃនោះតទៅ ( La Roue de la Loi Bouddhique )

សព្វថ្ងៃនេះ អ្នកកាន់ព្រះពុទ្ធសាសនា គោរពកង រឺ ចក្រនេះដោយសន្មត់ថាជាតួអង្គព្រះពុទ្ធ និងព្រះធម៌ ។

រដ្ឋាភិបាលនៃប្រទេសឥណ្ឌា ក្រោយពី គ.ស ១៩៤៧ បានសំរេចឆ្លាក់ត្រា មានរូបគោបួនឈរ និង រូបកងចក្រ ។ រីឯទង់ជាតិវិញ មានកងចក្រនៅចំកណ្តាល ដែលជានិមិត្តសញ្ញានៃឯកភាពជាតិ ។

ពានទាំងពីរ រឺ គុបភ្លើងតំកល់លើកងចក្រដែលទុកជាឃ្លាំងចំនេះវិជ្ជានោះ ជានិមិត្តរូបនៃអង្គបុគ្គលិកសិក្សាខ្មែរ ដែលមានការចេះដឹងតាមលំដាប់ថ្នាក់ស្រូបបានពីធម្មចក្ក ។ ចំនេះដឹងសន្សំបានបន្តិចម្តងៗ ក្លាយជាពន្លឺ គឺបញ្ញា ក្លាយជាសមត្ថភាព ក្លាយជាចរិត [(១)] ។

---

(១) ដូចត្របកផ្កាឈូកទាំងបីជានិមិត្តរូប ។ តាមព្រះពុទ្ធសាសនាផ្កាឈូកជានិមិត្តរូបនៃការត្រាស់ដឹង ព្រោះផ្កាឈូកដុះចេញពីភក់បាតបឹង បាតត្រពាំង ប៉ុន្តែផ្ការីកស្រស់ស្អាតលើទឹកឥតមានប្រឡាក់ រឺ ជំក្លិនភក់បន្តិចសោះឡើយ ។

សូមពិចារណាជាមួយខ្ញុំអំពីអណ្ដាតភ្លើង (la flamme) ។ ពានតូច ធំ ដាក់លើកងចក្រ ម្ដេចក៏បង្កើតបានអណ្ដាតភ្លើង បើគ្មានប្រេង និងប្រឆេះផង ? ភ្លើងនេះចេញមកពីណា ?

ការស្មីដែលផុះចេញពីអណ្ដាតភ្លើងជានិមិត្តរូបនៃការផ្ទេរចំនេះដឹងអោយទៅយុវវ័យ និងប្រជាពលរដ្ឋ ។ ប្រសិនបើលោកគ្រូ - អ្នកគ្រូ មិនទាន់មានពន្លឺច្បាស់ក្នុងខ្លួននៅឡើយទេ ពន្លឺដែលត្រូវផុះទៅអោយសិស្សនោះ ក៏មិនបានច្បាស់ល្អ គឺនៅព្រាលៗ មិនបានភ្លឺដូចពន្លឺថ្ងៃនៅឡើយទេ ។

ហេតុនេះ លោកគ្រូ - អ្នកគ្រូ គួរតែមានចំនេះដឹងទូលាយ ដើម្បីផ្សព្វផ្សាយអោយបានច្បាស់លាស់ មិត់ចត់ និងធ្វើជាគំរូល្អដល់បរិដ្ឋានសង្គមជុំវិញ ។

តទៅនេះ យើងពិនិត្យមើលរូបសញ្ញាក្រសួងអប់រំ កាលពីឆ្នាំ ១៩៧៩-១៩៩៣ និងពីឆ្នាំ ១៩៩៣ មកទល់បច្ចុប្បន្នកាលនេះ ។

កាលប្រទេសកម្ពុជា ស្ថិតនៅក្នុងប្លុកប្រទេសសង្គមនិយម (១៩៧៩-១៩៩៣) សញ្ញាក្រសួងអប់រំមានអត្ថន័យផ្សេង ។

វិចិត្រករក្រសួងអប់រំ បានគូរក្ងួរស្រូវជាតំណាងវណ្ណៈកសិករ ស្ពឺចក្រ (engrenage) ជាតំណាងវណ្ណៈកម្មករ សៀវភៅ និងដងប៉ាកា តំណាងវណ្ណៈបញ្ញវ័ន្ត ។

ស្រទាប់វណ្ណៈទាំងបីនេះ រួមសាមគ្គីជាធ្លុងមួយដើម្បីទ្រទ្រង់ប្រទេសជាតិ ដែលមានប្រាសាទកំពូលប្រាំជានិមិត្តរូប ។ នៅខាងលើស្រទាប់វណ្ណៈ មានគុបភ្លើងជានិមិត្តរូបនៃក្រសួងអប់រំ ជាអ្នកបំភ្លឺផ្លូវ ។ ខ្សែបូសំពត់ពណ៌ផ្ទៃមេឃចារិកអក្សរ ‹‹អ.រ›› ជានិមិត្តរូបទំនាក់ទំនងអន្តរជាតិ ។

រីឯរូបសញ្ញាដែលក្រសួងអប់រំស្នើសុំសេចក្ដីអនុញ្ញាតយកមកប្រើប្រាស់វិញ តាមលិខិតលេខ ៩៧ អ.យ.ក ចុះថ្ងៃទី ៣០-១២-៩៣ នោះ គឺរូបសញ្ញាក្រសួងជំនាន់សង្គមរាស្ត្រនិយម ។ តែអត្ថន័យ និងខ្លឹមសារត្រូវបានបកស្រាយដូចតទៅ ។

ក - រូបសញ្ញាមានរង្វង់មូលព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាស ជាតំណាងអោយវប្បធម៌ខ្មែរ និងជានិមិត្តរូបស្រទាប់យុវជនកំពុងសិក្សាអប់រំ ដែលមានការរីកចំរើនល្អតលាស់ជាផ្កា ជាផ្លែ របស់ប្រទេសជាតិទៅអនាគត ។

ខ - នៅចំកណ្ដាលពីលើកំរងផ្កាក្បាច់ភ្ញីទេស មានកងរង្វង់មូលទ្រភ្លើងគុបពណ៌មាស ជានិមិត្តរូបវិស័យកីឡា ដែលមានយុវវ័យជាអ្នកទ្រងទ្រង់ និងបន្តវេន ។

គ - នៅលើផ្ទៃសញ្ញា មានការស្មីពណ៌មាសចាំងបំភ្លឺគ្រប់ទិសទីលើផ្ទៃពណ៌ផ្ទៃមេឃ ជាពន្លឺនៃវិជ្ជាអប់រំ សតិបញ្ញា ស្មារតីដល់ប្រជាពលរដ្ឋខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ឃ - ក្រណាត់ខ្សែបូ ពណ៌ផ្ទៃមេឃដែលមានចារិកអក្សរពណ៌មាសក្រសួងអប់រំ យុវជន និងកីឡា ទ្រពីក្រោម ជានិមិត្តរូបវិស័យអប់រំសិក្សា ដែលមានទំនាក់ទំនងជាមួយអន្តរជាតិ(ចំលងតាមលិខិតក្រសួងអប់រំ) ។

ដើម្បីកិច្ចបញ្ចប់ការត្រិះរិះពិចារណារបស់ខ្ញុំទៅលើរូបសញ្ញាក្រសួងអប់រំទាំងបីរបបនយោបាយ ខ្ញុំសូមបុគ្គលិកសិក្សាទាំងអស់កំនត់ក្នុងចិត្តទុករូបសញ្ញាក្រសួងអប់រំ ជានិមិត្តរូបនៃអង្គរបស់ខ្លួន ព្រោះអ្នកអប់រំគ្រប់ជាន់ថ្នាក់ត្រូវតែមានចំនេះដឹងជ្រៅជ្រះ មានសមត្ថភាពគ្រប់គ្រាន់ក្នុងកិច្ចការរបស់ខ្លួន និងមានចរិយាធម៌ជាគំរូ ដើម្បីបង្ហាត់បង្រៀនយុវវ័យអោយឃើញនូវអ្វីទៅដែលហៅថា តំលៃមនុស្ស រឺ មនុស្សថ្លៃថ្នូរ ។

សូមបុគ្គលិកសិក្សាតាំងខ្លួនជាអ្នកកាន់ប្រទីបបំភ្លឺជាតិ ជាអ្នកកសាងប្រទេសជាតិអោយបានរុងរឿងខាងផ្នែកសំភារៈ និងស៊ីលធម៌ ។

**ដោយ លោក យ៉ិច់ ធី**



# ច្បាប់
## ស្តីពី
## សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
## នៃព្រះរាជាណាចក្រកម្ពុជា
## ជំពូកទី ១
## បញ្ញត្តិទូទៅ



**មាត្រា ១.**

អ្នករាជការក្របខ័ណ្ឌទាំងឡាយនៃព្រះរាជណាចក្រកម្ពុជា ក្រៅពីអ្នករាជការដែលស្ថិតនៅក្នុងក្រុមតុលាការ និងក្រុមនីតិបញ្ញត្តិដែលមានលក្ខណៈពិសេសនោះត្រូវស្ថិតនៅក្នុងសហវិធាននេះ ។

**មាត្រា ២.**

ច្បាប់នេះអនុវត្តចំពោះអ្នករាជការនៃព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខ័ណ្ឌទាំងពួងដែលបានបង្កើត និងរៀបចំឡើងតាមព្រះរាជក្រឹត្យ ហើយបានចូលធ្វើការនៅតាមក្រសួង ស្ថាប័ននានាដោយមានសិទ្ធិទទួលប្រាក់សោធននិវត្តន៍ ។

**មាត្រា ៣.**

ក្របខ័ណ្ឌទាំងឡាយនៃអ្នករាជការ ត្រូវកំណត់ដោយលក្ខន្តិកៈដោយឡែកតាមព្រះរាជក្រឹត្យ ។

**មាត្រា ៤.**

ប្រភេទក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ សន្ទស្សន៍បៀវត្សអ្នករាជការក្នុងព្រះរាជណាចក្រកម្ពុជា ព្រមទាំងលក្ខន្តិកៈដោយឡែកនៃអង្គផ្សេងៗ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

**មាត្រា ៥.**

ការតែងតាំង ការតំឡើងថ្នាក់ ការផ្លាស់ប្តូរ ការដាក់ក្រៅតំណែង រឺការដាក់អោយនៅក្រៅក្របខ័ណ្ឌ ត្រូវសំរេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ រឺ ប្រកាស ។

ការបញ្ឈប់លែងអោយធ្វើការដោយបង្ខំ ការដាក់អោយចូលនិវត្តន៍មុនកំណត់ និងការហួតងារនៃអ្នករាជការក្របខ័ណ្ឌ ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ រឺ ប្រកាស ស្របតាមលក្ខន្តិកៈដោយឡែកនៃអ្នករាជការនេះ ។

**មាត្រា ៦.**

អ្នករាជការម្នាក់ៗមានសិទ្ធិសុំមើលកំណត់ត្រា និងឯកសារផ្សេងៗដែលជាសំណុំរឿងផ្ទាល់ខ្លួន មុននិងត្រូវទទួលទណ្ឌកម្មខាងវិន័យ រឺមុននឹងត្រូវផ្លាស់ដោយបង្ខំ ។ សិទ្ធិដដែលនេះត្រូវបានអនុញ្ញាតអោយដល់អ្នករាជការណាដែលយឺតយូរមិនបានឡើងឋានន្តរស័ក្តិ រឺ ថ្នាក់តាមវេនអតីតភាព ។

**មាត្រា ៧.**

អ្នករាជការក្របខ័ណ្ឌអាចដាក់អោយទៅបំរើការ រឺ បំពេញមុខងារក្រៅពីក្របខ័ណ្ឌដើមរបស់ខ្លួនបាន ក្នុងករណីចាំបាច់ និងមានការយល់ព្រមពីសាមីខ្លួន ។

អ្នករាជការក្របខណ្ឌមានសិទ្ធិសុំផ្លាស់កន្លែងធ្វើការទៅតាមប្ដី រឺ ប្រពន្ធបាន ។

**មាត្រា ៨.**

នៅក្នុងក្របខ័ណ្ឌនីមួយៗ តាមគោលការណ៍ អ្នករាជការក្នុងឋានន្តរស័ក្តិ រឺ ថ្នាក់ណាមួយមិនអាចចាត់អោយទៅធ្វើការក្រោមបង្គាប់អ្នករាជការម្នាក់ទៀតដែលមានឋានន្តរស័ក្តិ រឺ ថ្នាក់ទាបជាងខ្លួនទេ លើកលែងតែក្នុងករណីចាំបាច់ហើយសាមីខ្លួនដែលមានឋានន្តរស័ក្តិ រឺ ថ្នាក់ធំជាងនោះយល់ព្រម ។

**មាត្រា ៩.**

របបស្តីពីការសុំច្បាប់ និងការឈប់សំរាកប្រចាំឆ្នាំ ប្រាក់បំណាច់បេសកកម្ម ប្រាក់បំណាច់ព្យាបាលរោគក្នុងមន្ទីរពេទ្យ និងប្រាក់សោធននិវត្តន៍ ។ ល ។ ត្រូវកំណត់តាមច្បាប់ដោយឡែក ។

**មាត្រា ១០.**

បៀវត្សនិងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ដូចជាប្រាក់បំណាច់បន្ថែមនិងប្រាក់បំណាច់ទទួលខុសត្រូវ ប្រាក់តំបន់ ប្រាក់ឧបត្ថម្ភកូននិងប្រពន្ធ ប្រាក់ថ្លៃឈ្នួលផ្ទះ ថ្លៃសង្ហារឹមក្នុងផ្ទះ ថ្លៃជាវមធ្យោបាយការងារ ថ្លៃទឹក និងថ្លៃភ្លើង ។ ល ។ នៃអ្នករាជការត្រូវកំណត់តាមច្បាប់ដោយឡែក ។

## ជំពូកទី ២

## ការជ្រើសរើសអោយចូលធ្វើការ

**មាត្រា ១១.**

បេក្ខជនទាំងពីរភេទអាចទទួលអោយចូលធ្វើការក្នុងក្របខ័ណ្ឌរាជការបាន លុះត្រាតែបេក្ខជននោះបានបំពេញនូវលក្ខខ័ណ្ឌដូចខាងក្រោម ៖

១- មានសញ្ជាតិជាខ្មែរ ។

២- មានអាយុយ៉ាងតិច ១៨ ឆ្នាំ ហើយមិនលើសពី ២៥ ឆ្នាំ ប៉ុន្តែមានករណីលើកលែងខ្លះដូចមានចែងខាងក្រោមនេះ ៖

ក - ចំពោះបេក្ខជនដែលមានសញ្ញាប័ត្រឧត្តមសិក្សា ការកំរិតអាយុ ត្រូវបានរំកិល ពី ២៥ ឆ្នាំ ដល់ ៣០ ឆ្នាំ យ៉ាងច្រើនបំផុត ។

ខ - ចំពោះបេក្ខជនដែលបានរៀននៅគ្រឹះស្ថានឧត្តមសិក្សា មួយឆ្នាំ រឺច្រើនឆ្នាំហើយ មិនបានសញ្ញាប័ត្រនោះ ការកំរិតអាយុ ២៥ ឆ្នាំ នឹងត្រូវរំកិលតាមចំនួនឆ្នាំ ដែលបានរៀនក្នុងគ្រឹះស្ថានឧត្តមសិក្សាទាំងនោះ តែមិនអោយលើសពីអាយុ ៣០ ឆ្នាំ ។

គ - ចំពោះបេក្ខជនដែលបានបំពេញកាតព្វកិច្ចយោធា ការកំរិតអាយុត្រូវរំកិលតាម ចំនួនឆ្នាំដែលបានបំពេញកាតព្វកិច្ចយោធានោះ ។

ឃ - ក្នុងពេលចាំបាច់ រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យលើកលែងការកំណត់អាយុ នៃបេក្ខជនដើម្បីបំពេញសេចក្តីត្រូវការជាអាទិភាព និងដើម្បីផលប្រយោជន៍ ជាតិ ។

៣- មិនបានប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិជាពលរដ្ឋ សិទ្ធិខាងនយោបាយ ។

៤- មិនដែលមានទោសឧក្រិដ្ឋ រឺ មជ្ឈិមពីរឿងល្មើសប៉ះពាល់ដល់ទំនៀមទំលាប់ កិត្តិយស និង ភាពសុចរិត ។

៥- ត្រូវមានកាយសម្បទាគ្រប់គ្រាន់ក្នុងការបំពេញការងារដែលលក្ខណៈសម្បត្តិមានចែងទុកជា មុននៅក្នុងសេចក្តីណែនាំ និងបទបញ្ញាជាធរមាន ។

៦- បងប្អូនជនជាតិភាគតិច បងប្អូននៅតំបន់ដាច់ស្រយាល និងបងប្អូននារីភេទអាចត្រូវបាន ផ្តល់អាទិភាព និងភាពងាយស្រួល ។

៧- ត្រូវបំពេញលក្ខខ័ណ្ឌសមត្ថភាពគ្រប់គ្រាន់ ដូចមានចែងក្នុងបទបញ្ញាដោយឡែកនៃអង្គដែល ខ្លួនមានបំណងសុំចូលបំរើការងារ ។

## មាត្រា ១២.

លក្ខខ័ណ្ឌស្តីពីសញ្ជាតិ និងអាយុត្រូវបញ្ជាក់តាមសំបុត្រអត្រានុកូលដ្ឋាន រឺតាមសាលក្រមជំនួស អត្រានុកូលដ្ឋាននោះ ។

សេចក្តីបញ្ជាក់ថាគ្មានទោសត្រូវកំណត់ក្នុងសំបុត្រថ្កោលទោសមួយមានសុពលភាព ៣ ខែ ដែលចេញ ដោយក្រសួងយុត្តិធម៌ ។

## មាត្រា ១៣.

ជាគោលការណ៍ រាល់ការជ្រើសរើសបេក្ខជនអោយចូលក្នុងក្របខ័ណ្ឌ ត្រូវធ្វើឡើងតាមការប្រឡង ប្រជែង លើកលែងតែមានការកំណត់ផ្សេងពីនេះដោយរាជរដ្ឋាភិបាល ។

## មាត្រា ១៤.

កាលបរិច្ឆេទនៃការប្រឡងប្រជែងជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌរាជការ ត្រូវកំណត់ និងផ្សព្វផ្សាយ យ៉ាងតិច ៣ ខែមុនថ្ងៃដែលបើកអោយចូលប្រឡង ។ ក្នុងករណីដែលមានការប្រញាប់ ការផ្សព្វផ្សាយត្រូវធ្វើ យ៉ាងតិច ៣០ ថ្ងៃ ។

**មាត្រា ១៥.**

ជាគោលការណ៍ រាល់ការប្រឡងប្រជែងជ្រើសរើសអោយចូលក្របខ័ណ្ឌរាជការ ត្រូវមានតំណាងស្ថាប័នមុខងារសាធារណៈចូលរួម ។

## ជំពូកទី ៣
## ការធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ
## ការបញ្ចេញពីក្របខ័ណ្ឌ

**មាត្រា ១៦.**

ការតាំងស៊ប់ក្នុងក្របខ័ណ្ឌរាជការនឹងអាចសំរេចបានជាស្ថាពរ ក្រោយពីបានធ្វើកម្មសិក្សាសាកល្បងមួយ ។ ផ្ទុយទៅវិញ អាចលើកលែងមិនបាច់ធ្វើកម្មសិក្សា ចំពោះបេក្ខជនទាំងឡាយដែលបានប្រឡងជាប់ទៅកាន់ប្រភេទក្របខ័ណ្ឌខ្ពស់ជាងនៃអង្គដែលខ្លួនធ្លាប់ជាមន្ត្រី រាជការចាស់តាំងស៊ប់ក្នុងក្រខ័ណ្ឌម្តងរួចហើយ ។

**មាត្រា ១៧.**

បៀវត្សរបស់កម្មសិក្សាការីត្រូវកាត់ទុកប្រាក់សំរាប់សោធននិវត្តន៍ ។ បើសិនជាកម្មសិក្សាការីនោះមិនបានតាំងស៊ប់ក្នុងក្របខ័ណ្ឌរាជការទេនោះ ប្រាក់ដែលបានចាត់ទុកសំរាប់សោធននិវត្តន៍នេះត្រូវសងមកសាមីខ្លួនវិញ ។

**មាត្រា ១៨.**

រយៈពេលកម្មសិក្សាត្រូវកំរិត ១២ ខែ ។ រយៈពេលកម្មសិក្សាត្រូវគិតពីថ្ងៃតែងតាំងកម្មសិក្សាការីនោះ ។ កម្មសិក្សានេះមិនត្រូវយកជាការបានទេ បើកាលណាសាមីជនអាក់ខានមកធ្វើកម្មសិក្សា សរុបលើសពី ៣០ ថ្ងៃ ។ ក្នុងករណីនេះ សាមីជនត្រូវបន្តធ្វើកម្មសិក្សានៅឆ្នាំទី ២ ទៀត ។

- ការតាំងស៊ប់ក្នុងក្របខ័ណ្ឌរាជការនឹងធ្វើទៅបាន លុះត្រាតែកម្មសិក្សាការីបានបំពេញកម្មសិក្សាចំនួន ១២ ខែជាពិតប្រាកដ ។ រយៈពេលកម្មសិក្សានេះត្រូវបន្ថយ ៦ ខែចំពោះមន្ត្រីរាជការក្របខ័ណ្ឌចាស់ដែលបានប្រឡងជាប់ចូលក្របខ័ណ្ឌថ្មីមួយ ដោយរក្សាអតីតភាពដែលមានពីមុន ។

  ការតាំងស៊ប់ក្នុងក្របខ័ណ្ឌត្រូវធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចតែងតាំង តាមសំណើពីប្រធានអង្គភាព ។ ការតែងតាំងស៊ប់នៃកម្មសិក្សាការីត្រូវតែមានការរួមយោបល់ពីគណៈកម្មការមួយ ។

## សមាសភាពគណៈកម្មការនេះមាន

១- ប្រធានស្ថាប័ន ឬ តំណាង ប្រធាន
២- ប្រធានអង្គភាពដែលគ្រប់គ្រង ឬតំណាង សមាជិក
៣- ប្រធានការិយាល័យបុគ្គលិក ឬតំណាង សមាជិក
៤- អ្នករាជការមួយរូបដែលមានក្របខ័ណ្ឌជាមួយគ្នា សមាជិក

កម្មសិក្សាការីណាដែលមិនបានបង្ហាញអោយឃើញថាខ្លួនមានសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់ ឬក៏ពិនិត្យឃើញថារបៀបធ្វើការងារមានការខ្វះខាត ឬក៏គ្មានកំលាំងពលំនឹងកាន់មុខតំណែងបាន តាមលក្ខខ័ណ្ឌដែលបានកំណត់ក្នុងសេចក្តីណែនាំជាធរមាន អាចបញ្ឈប់មិនអោយធ្វើការនេះពេលណាក៏បានក្នុងរយៈពេលកម្មសិក្សា ។ ត្រូវបញ្ឈប់មិនអោយធ្វើការដូចគ្នាដែរ ចំពោះអ្នករាជការណាដែលបានប្រព្រឹត្តបទល្មើសនឹងមាត្រា ៣៣ និងមាត្រាបន្តបន្ទាប់ទៅមុខទៀតនៃច្បាប់នេះ ដែលចែងពីការដាក់វិន័យចំពោះមន្ត្រីរាជការ ។

ការបញ្ឈប់មិនអោយធ្វើការ ឬការតាំងស៊ប់ក្នុងក្របខ័ណ្ឌ តោងតែសំរេចជាដាច់ខាតក្នុងរយៈពេល ៣ ខែក្រោយថ្ងៃផុតកំណត់រយៈពេលកម្មសិក្សា ១២ ខែកន្លងមក ។ ការតែងតាំងស៊ប់ក្នុងក្របខ័ណ្ឌចាប់ផ្តើមមានប្រសិទ្ធភាព ក្នុងផ្នែកបៀវត្ស ក៏ដូចជាអតីតភាពការងារសំរាប់ឡើងឋានន្តរស័ក្តិ ឬថ្នាក់ ចាប់ពីថ្ងៃផុតកំណត់នៃកម្មសិក្សានេះ ។ ប៉ុន្តែអតីតភាពការងារសំរាប់ចូលនិវត្តន៍ត្រូវបានគិតបញ្ចូលតាំងពីថ្ងៃចាប់ផ្តើមធ្វើកម្មសិក្សា ។

## មាត្រា ១៩.

អ្នករាជការណាដែលធ្វើការតទៅមិនបាន ដោយហេតុមកពីបាត់បង់សម្បទាវិជ្ជាជីវៈ ហើយដែលមិនបានបំពេញលក្ខខ័ណ្ឌគ្រប់គ្រាន់ ដើម្បីទទួលសោធននិវត្តន៍អាចនឹងត្រូវបញ្ឈប់មិនអោយធ្វើការតទៅទៀតនៅពេលណាក៏បាន ។

អ្នករាជការមានអតីតភាពការងារចាប់ពី ២០ ឆ្នាំឡើងទៅ ដែលតំរូវអោយចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ មានសិទ្ធិទទួលសោធនសមាមាត្រ ។ បើអតីតភាពការងារក្រោម ២០ ឆ្នាំ អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ មានសិទ្ធិទទួលប្រាក់រស់ ដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់រដ្ឋតែមួយលើក ។

ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវសំរេចដោយគណៈកម្មការមួយដែលមានសមាសភាពដូចខាងក្រោមនេះ ៖

១- ប្រធានស្ថាប័ន ឬតំណាង ប្រធាន
២- ប្រធានអង្គភាពដែលគ្រប់គ្រង ឬតំណាង សមាជិក
៣- ប្រធានការិយាល័យបុគ្គលិក ឬតំណាង សមាជិក
៤- គ្រូពេទ្យដែលបានទទួលសច្ចាប្រណិធាន ហើយដែលចាត់តាំងឡើងដោយក្រសួងសុខាភិបាល សមាជិក
៥- អ្នករាជការដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នាពីរនាក់ដែលមានឋានន្តរស័ក្តិយ៉ាងហោចណាស់ស្មើនឹងសាមីខ្លួន សមាជិក

## ព្រះរាជាណាចក្រកម្ពុជា

ក្រសួងអប់រំ យុវជន និង កីឡា          ជាតិ  សាសនា  ព្រះមហាក្សត្រ

**** * ****          **** * ****

លេខ : ១៥៩៧ អយក.ហវ.          ភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៥

## រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

**ជំរាបមក**

## លោកប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត -ក្រុង

ក ម្ម វ ត្ថុ : ការណែនាំស្វ័យសិក្សា ឯកសារបណ្ដុះបណ្ដាលពីចំងាយ ជូនគ្រូបឋមសិក្សា ។

យោ ង : លិខិតលេខ ១០៣២ អយក.ហវ. ចុះថ្ងៃទី ៤ ឧសភា ១៩៩៥ ។

តតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបអស់លោកថា ដើម្បីអោយការអនុវត្តស្វ័យសិក្សាឯកសារបណ្ដុះបណ្ដាលពីចំងាយទទួលបានទិន្នផលខ្ពស់ ក្រសួងអប់រំយុវជន និង កីឡា សូមធ្វើការណែនាំដូចតទៅ ៖

**១- មុខសញ្ញាទទួលការបណ្ដុះបណ្ដាលពីចំងាយ :**

+ លោកគ្រូ - អ្នកគ្រូ ជាសិក្ខាបទធារី និង ជាគ្រូជំនួយទាំងអស់ដែលកំពុងបង្រៀននៅតាមសាលាបឋមសិក្សាទូទាំងប្រទេស ។

+ លោកនាយក - នាយករងនៅតាមសាលាបឋមសិក្សាទូទាំងប្រទេស ។

+ លោកគ្រូ - អ្នកគ្រូផ្នែករដ្ឋបាលទោះស្ថិតក្នុងក្របខ័ណ្ឌណាក្ដី ដែលកំពុងបំរើការផ្នែកបឋមសិក្សានៅតាមអង្គភាពចំនុះទីស្ដីការ - មន្ទីរអប់រំខេត្ត - ក្រុង ការិយាល័យអប់រំស្រុក - ខ័ណ្ឌ - សាលាបឋមសិក្សាទូទាំងប្រទេស ។

ចំពោះគណៈគ្រប់គ្រង គ្រូឧទ្ទេស និង លោកគ្រូ - អ្នកគ្រូផ្នែករដ្ឋបាល ក្នុងសាលាគរុកោសល្យខេត្ត - ក្រុង ទទួលឯកសារធ្វើស្វ័យសិក្សា តែទទួលប្រាក់កំរៃឧបត្ថម្ភក្នុងកម្មវិធីបណ្ដុះបណ្ដាលដំបូង ( Formation initiale ) ។

**២- វិធីស្វ័យសិក្សា :**

គ្រូបឋមសិក្សាម្នាក់ៗ តាមមុខសញ្ញាខាងលើត្រូវបានទទួលកំរងឯកសារ ចំនួន ៣ ទន្ទឹមគ្នា ជារៀងរាល់ខែគឺ ៖

+ ខ្លឹមសារឯកសារភាសាខ្មែរ និង គណិតវិទ្យា ( សំរាប់បង្កើនសមត្ថភាពចំនេះដឹងផ្ទាល់ខ្លួនក្នុងការបង្រៀន ) ។

+ កំណែលំហាត់ ( សំរាប់ស្វ័យត្រួតពិនិត្យកំណែលំហាត់ក្នុងខ្នឹមសារមេរៀននីមួយៗ ) ។

+ កិច្ចការ ( សំរាប់វាយតំលៃការយល់ដឹងនៃបុគ្គលម្នាក់ៗ ក្រោយពេលធ្វើស្វ័យសិក្សាលើខ្លឹមសារឯកសារ ) ។

នៅលើក្របកិច្ចការនីមួយៗ មានបោះត្រាលេខរៀងពណ៌ក្រហម ។ លោកនាយកសាលាមានភារៈកិច្ចទទួលខុសត្រូវត្រួតពិនិត្យ និង បែងចែកឯកសារ ដោយណែនាំលោកគ្រូ - អ្នកគ្រូទាំងអស់អោយបំពេញឈ្មោះលើក្របកិច្ចការដូចខាងក្រោម :

- ខេត្ត - ក្រុង............... ខ័ណ្ឌ - ស្រុក............. សង្កាត់ - ឃុំ ............
- ឈ្មោះសាលារៀន ..............................................................
- នាម និង គោត្តនាម ............................................................
- លេខកិច្ចការ ....................................................................
- មុខងារ ........................... ក្របខ័ណ្ឌ ...............................

ពិន្ទុ : - ភាសាខ្មែរ ឈ្មោះអ្នកកែ
- គណិតវិទ្យា

ក្រោយពេលធ្វើស្វ័យសិក្សា លោកគ្រូ - អ្នកគ្រូត្រូវធ្វើ ‹‹ កិច្ចការ ›› ដោយខ្លួនឯង និងតាមសមត្ថភាពយល់ដឹងរៀងៗ ខ្លួន រួចប្រគល់ជូនលោកនាយកសាលា ។ លោកនាយកសាលាចុះឈ្មោះ និងចុះលេខរៀងកិច្ចការទាំងអស់លើតារាងសំរង់ពិន្ទុផ្ទួនភ្ជាប់ ហើយត្រូវយកតារាងនោះធ្វើជាដីការអមភ្ជាប់ជាមួយកិច្ចការតាមឯកសារភាគនីមួយៗ បញ្ជូនទៅលោកប្រធានការិយាល័យអប់រំខ័ណ្ឌ - ស្រុក ។

លោកប្រធានការិយាល័យអប់រំខ័ណ្ឌ - ស្រុក ត្រួតពិនិត្យតារាងឈ្មោះ និង កិច្ចការគ្រប់សាលារៀន ហើយជ្រើសរើសអ្នកកែ ( គ្រូមធ្យមសិក្សាកំរិត ១ រឺ គ្រូមធ្យមសិក្សាកំរិត ២ ) ពី ២ ទៅ ៤ នាក់ តាមចំនួនសមាមាត្រគ្រូដែលមាននៅក្នុងខ័ណ្ឌ - ស្រុកនីមួយៗ ។ កំនែត្រូវដាក់ពិន្ទុ ( ១០ លើ ១០ ផ្នែកភាសាខ្មែរ និង ១០ លើ ១០ ផ្នែកគណិតវិទ្យា ) ហើយត្រូវចុះពិន្ទុនោះតាមឈ្មោះក្នុងតារាងសំរង់ពិន្ទុ ឯកសារភាគ១ រឺ ភាគ ២ រឺ ភាគ៣ តាមការជាក់ស្តែង ។

នៅពេលចុះពិន្ទុកិច្ចការក្នុងតារាងសំរង់ពិន្ទុឯកសារភាគ ៣រួច ប្រធានការិយាល័យអប់រំខ័ណ្ឌ ស្រុក និង អ្នកកែ ត្រូវធ្វើការត្រួតពិនិត្យកិច្ចការម្តងទៀត ដោយចុះហត្ថលេខាទទួលខុសត្រូវ រួចផ្ញើតារាងទៅប្រធានមន្ទីរអប់រំខេត្ត - ក្រុង ។ រីឯកិច្ចការទាំងអស់ត្រូវផ្ញើត្រលប់ជូនសាមីជនដើមវិញ ។ ( សហគមន៍អឺរ៉ុបនឹងជួយឧបត្ថម្ភប្រាក់កំរៃកំនែជូន អ្នកកែ ) ។

ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្ត - ក្រុង ត្រូវសហការជាមួយអ្នកពិគ្រោះការ និង ក្រុមការងារថ្នាក់ខេត្តរបស់ PASEC ដើម្បីប្រមូលផ្តុំ និង ពិនិត្យតារាងសំរង់ពិន្ទុទាំងអស់ ចុះចំនួនប្រាក់កំរៃ ដែលលោកគ្រូ - អ្នកគ្រូត្រូវបានទទួលតាមចំនួនកិច្ចការដែលបានធ្វើ ហើយចុះហត្ថលេខាទទួលខុសត្រូវ រួចបញ្ជូន

តារាងទាំងអស់ ចុះចំនួនប្រាក់កំរៃ ដែលលោកគ្រូ - អ្នកគ្រូត្រូវបានទទួលតាមចំនួនកិច្ចការដែលបានធ្វើ ហើយចុះហត្ថលេខាទទួលខុសត្រូវ រួចបញ្ជូនតារាងទាំងអស់ទៅនាយកដ្ឋានផែនការ - ហិរញ្ញកិច្ច ១ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ ១ច្បាប់ នាយកដ្ឋានចាត់តាំង ១ច្បាប់ និង ទីស្នាក់ការ PASEC ១ច្បាប់ ដើម្បីរៀបចំធ្វើប្រាក់កំរៃជូនគ្រូបឋមសិក្សាទូទាំងប្រទេស តាមប្រភេទប្រាក់ឧបត្ថម្ភ ។

**៣- ការឧបត្ថម្ភប្រាក់កំរៃ :**

- ប្រាក់កំរៃឧបត្ថម្ភ សំរាប់ការបំប៉នតាមរយៈការបណ្តុះបណ្តាលពីចំងាយ ចែកចេញជាពីរប្រភេទ :

*ក. ចំពោះខេត្តវាលរាប*

លោកគ្រូ - អ្នកគ្រូម្នាក់ៗ ដែលមានឈ្មោះក្នុងបញ្ជីស្ម័យសិក្សាទទួលបានប្រាំមួយដុល្លាអាមេរិក (US $ 6) ក្នុងឯកសារបណ្តុះបណ្តាលពីចំងាយមួយភាគ ។

*ខ. ចំពោះខេត្ត និង តំបន់ដាច់ស្រយាល ( បញ្ជីភ្ជាប់ )*

លោកគ្រូ - អ្នកគ្រូម្នាក់ៗ ដែលមានឈ្មោះក្នុងបញ្ជីស្ម័យសិក្សាទទួលបាន ដប់ពីរដុល្លាអាមេរិក (US $ 12) ក្នុងឯកសារបណ្តុះបណ្តាលពីចំងាយមួយភាគ ។

**កំនត់សំគាល់ :**

- ប្រាក់កំរៃឧបត្ថម្ភខាងលើ និងបើកសរុបជូនបុគ្គលម្នាក់ៗ ក្នុងមួយឆ្នាំតុលម្តង ( បីឯកសារ ) គឺ : ( 3x US $ 6 = US $ 18 ) ចំពោះខេត្តវាលរាប និង ( 3x US $ 12 = US $ 36 ) ចំពោះខេត្ត និង តំបន់ដាច់ស្រយាល ។

- ចំពោះមុខសញ្ញាអង្គភាពចំនុះទីស្តីការ លោកប្រធានអង្គភាពត្រូវផ្ញើតារាងសំរង់កិច្ច ដែលមានចុះហត្ថលេខារបស់លោកគ្រូ - អ្នកគ្រូម្នាក់ៗ និងហត្ថលេខាប្រធានអង្គភាពទទួលខុសត្រូវ ភ្ជាប់ជាមួយកិច្ចការតាមឯកសារភាគនីមួយៗ ផ្ញើទៅនាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ ដើម្បីធ្វើកំរៃ ។

អាស្រ័យហេតុនេះ សូមលោកប្រធានធ្វើការផ្សព្វផ្សាយការណែនាំខាងលើ អោយបានទូលាយដល់ជូរគ្រូបឋមសិក្សាទាំងអស់ដែលមានក្នុងខេត្ត ក្រុង និង អង្គភាពរបស់អស់លោក អោយមានប្រសិទ្ធភាពខ្ពស់ ។

**ចម្លងជូន :**

- គ្រប់សាលាខេត្ត - ក្រុង
« ដើម្បីជ្រាបជាពតិមាន និង ជួយសហការ »
- គ្រប់អង្គភាពចំនុះទីស្តីការ " ដើម្បីជាពតិមាន "
- PASEC " ដើម្បីសហការ និង ជួយឧបត្ថម្ភ "
- កាលប្បវត្តិ.
- ឯកសារ : នា.បណ្តុះបណ្តាល និង វិក្រឹតការ




## លើកកំពស់ស្មារតីស្រឡាញ់មតិកនៃបុព្វបុរសខ្មែរ

បច្ចុប្បន្នកាលនេះ ប្រទេសកម្ពុជាបានធ្លាក់ចូលទៅក្នុងស្ថានភាពគួរអោយព្រួយបារម្ភ ។ វាខុសប្លែកខ្លាំងពីទសវត្សរ៍មុន ក្នុងបណ្តាឆ្នាំ ១៩៥០ និង ១៩៧០ ។ នេះគឺបណ្តាលមកពីសង្គ្រាមបង្ហូរឈាមជាតិសាសន៍ឯងអស់ពេលយ៉ាងយូរ ហើយសព្វថ្ងៃមិនទាន់ទាំងបញ្ចប់នៅឡើយផង ។ មហិច្ឆិតាដ៏ពិសពុល និង ដ៏អាស្រូវនេះបានលុបបំបាត់សីលធម៌ និង គោលធម៌ដ៏ប្រពៃរបស់ជាតិ ។ ជាពិសេសក្នុងរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ នៃរបបព្រៃផ្សៃ សង្គមខ្មែរត្រូវហិនហោចខ្ទេចខ្ទីជាទីបំផុត ដែលសកលលោកមិនដែលជួបប្រទះ ហើយរបបនេះបាននាំមកនូវអំពើដ៏សាហាវឃោរឃៅ ពោរពេញដោយការកាប់សំលាប់គួរអោយរន្ធត់ ។ លទ្ធផលនៃរបបដ៏ចង្រៃនេះគឺ :

- ប្រជាពលរដ្ឋស្លូតត្រង់ជាង ៣លាន នាក់ ត្រូវបាត់បង់ជីវិត
- អ្នកនៅសល់ពីការកាប់សំលាប់ មានជំងឺរ៉ាំរ៉ៃ បាក់កំលាំង
- កុមារា កុមារី ស្គមរីងរៃ
- វប្បធម៌ អក្សរសាស្ត្រ និង សិល្បៈរបស់ជាតិត្រូវបំផ្លាញ
- ភាពក្រីក្រហេមហាម និង ភាពហឹង្សាដ៏កំរោល ដែលយើងរាល់គ្នាមើលឃើញសព្វថ្ងៃ

ទាំងអស់នេះ ជាលទ្ធផលដែលបន្សល់ទុកដោយរបបដ៏ចង្រៃដែលយើងបានស្គាល់ និង បានដឹងគ្រប់ៗគ្នា ។

មកដល់ពេលនេះ ប្រទេសកម្ពុជាយើងដែលកាលពីមុន មុនឆ្នាំ ៧០ ជាប្រទេសមួយកំពុងធ្វើដំណើរទៅកាន់អភិវឌ្ឍន៍មិនចាញ់ប្រទេសជិតខាងនៅតំបន់អាស៊ីនេះ បានក្លាយទៅជាប្រទេសមួយដែលគេចាត់ទុកថា ជាប្រទេសក្រជាងគេក្នុងបណ្តាប្រទេសក្រទាំង ១០ នៅក្នុងពិភពលោក ។ ភាពក្រីក្រហេមហាមនេះ បានបង្កអោយមានជនអនាថា គ្មានទីពឹង គ្មានទីជំរក រស់នៅតាមចិញ្ចើមថ្នល់ ដើរសុំទាន ធ្វើពេស្យាចារ និង ចោរលួច ឆក់ប្លន់ ។ល។ ដែលជាបន្ទុកដ៏ធ្ងន់ធ្ងរនៃសង្គមបច្ចុប្បន្ន ក្នុងនោះក្រសួងអប់រំយុវជន និង កីឡា ដែលមានលោកគ្រូអ្នកគ្រូជាអ្នកទទួលបន្ទុកផ្ទាល់ ។

កុមារា កុមារី កើតក្រោយខែ មករា ១៩៧៩ រហូតមកដល់ពេលនេះ គេមានអាយុ ១៦ឆ្នាំហើយ គេមិនបានស្គាល់នូវភេរវកម្មនៃរបបអមនុស្សធម៌នោះឡើយ តែគេបានទទួលឥទ្ធិពលនៃរបបសង្គមនោះតាមរយៈមនុស្ស និង សង្គមដែលគេបំពាក់បាន ។ ដោយសារមូលហេតុនេះ អំពើខុសឆ្គង ពាលាអាវ៉ាសែ ការកាប់សំលាប់គ្នា តែងកើតមាននៅក្នុង

ផ្លូវយុវជនយើងមួយចំនួន ខុសប្លែកពីចរិយាធម៌ត្រឹមត្រូវ ថ្លៃថ្នូរ និង មានសណ្ដាប់ធ្នាប់ល្អ សមរម្យរបស់ជនជាតិខ្មែរយើង ដែលធ្លាប់មានតាំងពីសម័យដើមមក ។

បញ្ហាទាំងអស់នេះ គឺជាបញ្ហាដែលយើងត្រូវតែរកពុន និង ដោះស្រាយនៅក្នុងវិស័យអប់រំរបស់យើង ។ បើពុំនោះ បញ្ហាទាំងអស់នេះ នៅតែអូសបន្លាយវែងឆ្ងាយតទៅទៀតដែលជាកត្តាធ្វើអោយរាំងស្ទះដល់ការរីកចំរើនរបស់ប្រទេសជាតិ និងធ្វើអោយជាតិរបស់យើងអាប់កិត្តិយស ។

ក្នុងទស្សនៈនៃការអប់រំ យើងពុំត្រូវអស់សង្ឃឹមថា ធ្វើមិនកើត អប់រំមិនបាន ដេកផ្សងព្រេងវាសនានោះទេ ។ ពោលគឺ អ្វីៗ ទាំងអស់អាចអប់រំ កែប្រែបាន ។ ក្នុងតួនាទីជាអ្នកអប់រំ យើងសប្បាយចិត្តនឹងបំពេញភារកិច្ចនេះដោយអស់ពីចិត្តពីថ្លើម ។ តែក្នុងការលើកកំពស់វិស័យអប់រំ និង ការកែប្រែធនធានមនុស្សនេះ ពុំមែនស្ថិតតែនៅក្នុងដៃគ្រូបង្រៀនប៉ុណ្ណោះទេ តែត្រូវមានការចូលរួមពីសង្គម ពីរាជរដ្ឋាភិបាល និងមានការជួយឧបត្ថម្ភពីសំណាក់បណ្ដាប្រទេសជាមិត្តជិតឆ្ងាយ និង ពីបណ្ដាអង្គការអន្តរជាតិនានានៅលើសកលលោក ។ ដំបូង គេត្រូវចាប់ផ្ដើមពីការរៀបចំកម្មវិធីសិក្សានៅគ្រប់កំរិតសិក្សាអោយស៊ីចង្វាក់គ្នា ដោយមានគោលបំណងបាញ់ឆ្ពោះទៅរកការអភិវឌ្ឍន៍ជាតិ ផ្ដល់ចំណេះដឹងវិទ្យាសាស្ត្របច្ចេកទេស និង វិធីសាស្ត្របង្រៀនអោយទូលំទូលាយដល់លោកគ្រូ អ្នកគ្រូនៅគ្រប់កំរិតសិក្សា និង លើកកំពស់ជីវភាពគ្រូបង្រៀនអោយសមរម្យ ។

ដើម្បីលើកកំពស់វិស័យអប់រំ ដើម្បីអោយលទ្ធផលនៃការអប់រំបានសំរេចតាមបំណងប្រាថ្នា និង អោយមានកំរិតប្រហាក់ប្រហែលគ្នានឹងបណ្ដាប្រទេសនៅក្នុងតំបន់ និង ដើម្បីអោយសិស្ស - និស្សិតមានស្មារតីស្រឡាញ់ជាតិ ការពារកេតនភ័ណ្ឌជាតិ ចាំបាច់ត្រូវរៀបចំការងារដែលបានរៀបរាប់ខាងលើនេះ ។ ការងារទាំងអស់នេះ បានពាក់ព័ន្ធនឹងបញ្ហាផ្សេងៗ ជាច្រើន ព្រមទាំងអាចជួបប្រទះនឹងបញ្ហាស្មុគស្មាញថែមទៀតផង ។

នាពេលនេះ យើងសូមលើកយកមរតកនៃបុព្វបុរសខ្មែរមកបង្ហាញ ដើម្បីជាជំនួយស្មារតីដល់លោកគ្រូ - អ្នកគ្រូក្នុង ការអប់រំសិស្ស - និស្សិត សំដៅអោយគេទាំងឡាយយល់ពីជាតិ ពីទឹកដី ពីស្នាដៃវប្បធម៌ និងពីអ្វីដែលគេត្រូវធ្វើទៅអនាគត ដើម្បីបុព្វហេតុជាតិ សាសនា ព្រះមហាក្សត្ររបស់គេ ។

ដំបូងគួរយល់ តើមរតកបុព្វបុរសខ្មែរមានអ្វីខ្លះ ?

មរតកនៃបុព្វបុរសខ្មែរមានពីរយ៉ាង គឺ :

### ១- កេរមរតកធម្មជាតិ :

ប្រទេសកម្ពុជាសព្វថ្ងៃមានផ្ទៃដី ១៨១.០៣៥ គម.$^{២}$ ។ នៅលើវិសាលភាពទឹកដីនេះមានប្រវត្តិសប្បាយរីករាយក៏មាន និង ជូរចត់ក៏មាន ។ បុព្វបុរសដូនតាខ្មែរបានពលីយ៉ាងប្ដូរផ្ដាច់ដ៏ច្រើនមហិមា តស៊ូនឹងសត្រូវដែលប្រាថ្នាចង់បានទឹកដីនេះធ្វើជាទ្រព្យសម្បត្តិរបស់គេ អស់រយៈពេលរាប់សិបទសវត្សមកហើយ ។

នៅលើទឹកដីនេះ សំបូរទៅដោយធនធានធម្មជាតិ ធនធានក្នុងដី និង លើដី ដូចជា : ព្រៃឈើ ទន្លេ បឹងបួ សមុទ្រ និង ផ្ទៃដីស្រែចំការមានជីជាតិដ៏ធំល្វឹងល្វើយ ដែលបង្កលក្ខណៈងាយស្រួលដល់ជីវភាពកូនចៅជំនាន់ក្រោយ ។ ធនធាន រឺ មរតកទាំងនេះ ប្រសិនបើចេះការពារ ចេះថែរក្សា ចេះទាញយកផលតាមវិចារណញ្ញាណ នោះមិនអាចហិនហោចដូចសព្វថ្ងៃនេះទេ ។ គ្រោះទឹកជំនន់ ខ្យល់ព្យុះ និង គ្រោះរាំងស្ងួត ដែលមានកើតឡើងខុសពីប្រក្រតី តើបណ្ដាមកពីអ្វី ? មកពីព្រៃឈើរាប់ពាន់ហិកតា ត្រូវបានកាប់បំផ្លាញក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក ។ គេបង្គាប់អោយកាប់ឈើលើភ្នំ ដើម្បីធ្វើចំការ គេលក់ឈើអោយបរទេស ដើម្បីយកប្រាក់ធ្វើជាទុនសំរាប់ទិញសំភារៈសឹកសំលាប់ខ្មែរគ្នាឯង

បន្តទៀត ។ ប្រការនេះ គេអាចសួរថា តើនរណាជាអ្នកបំផ្លាញ ? តើអ្នកបំផ្លាញនោះដឹងពីគ្រោះថ្នាក់ រឺទេ ? យើងឆ្លើយថា គេដឹង តែគេធ្វើមិនដឹង ដោយគេគិតតែទៅលើរឿងមួយ គឺយកមាសទៅធ្វើមធ្យោបាយបន្តសង្គ្រាម ។ ពោលគឺ គេខ្វះមនសិការជាតិ ។ ទោះបីកម្ពុជាក្លាយជាវាលរហោស្ថាន ដូចជាវាលសាហារ៉ានៅអាហ្វ្រិចក៏ដោយ ក៏គេមិនឈឺក្បាលដែរ ។

រីឯពពែជ្រូ ត្បូង នៅប៉ៃលិន គេកកាយយកទៅធ្វើជាសេដ្ឋីអស់រលីង ។

ចំណែកមច្ឆាជាតិ ទាំងត្រីទឹកសាប និង ត្រីទឹកប្រៃក៏ត្រូវបំផ្លិចបំផ្លាញដូចគ្នា ដែលគួរអោយព្រួយបារម្ភ ។

កត្តាអសកម្មទាំងអស់នេះ បណ្ដាលមកពីខ្មែរខ្សោយ ខ្មែរបែកបាក់គ្នា ដែលជាឱកាសដ៏ល្អសំរាប់ជនជាតិបរទេស គេមានបំណងកេងប្រវញ្ចនិង ឈ្លានពានទឹកដីដើម្បីជាប្រយោជន៍ជាតិគេ ។

តើអ្នកអប់រំ នៅចំពោះស្ថានភាពបែបនេះ ត្រូវធ្វើយ៉ាងណា ? លោកគ្រូ - អ្នកគ្រូ ត្រូវធ្វើយ៉ាងណាអោយយុវជន យុវនារី ជំនាន់នេះយល់ច្បាស់ពីផលប្រយោជន៍នៃមរតកធម្មជាតិ និង ចូលរួមជាមួយរាជរដ្ឋាភិបាលថែរក្សា និង ការពារសម្បត្តិដែលដូនតាបានរក្សាទុកជាកេរមរតករហូតមកដល់សព្វថ្ងៃ ។

### ២- កេរមរតកវប្បធម៌ :

វប្បធម៌ជាព្រលឹងរបស់ជាតិ ។ ដើម្បីអោយជ្រួតជ្រាប និង យល់បានទូវឃ្លានេះ យើងគួរតែយល់ពាក្យ **វប្បធម៌** និង ពាក្យ **ព្រលឹង** ជាមុនសិន ។

វប្បធម៌ មានន័យទូលំទូលាយណាស់ មិនអាចពន្យល់អោយបានសព្វគ្រប់ឡើយ ។ ក្នុងទីនេះ យើងមិនលើកយកពាក្យវប្បធម៌ ដែលមានន័យថា ចំនេះទូទៅនោះ មកធ្វើអត្ថាធិប្បាយជូនទេ ។ យើងលើកតែវប្បធម៌ដែលជាមរតកនៃបុព្វបុរស រួមមាន ភាសា អក្សរសាស្ត្រ អក្សរសិល្ប៍ សិល្បៈ សាសនា ទំនៀមទំលាប់ ប្រពៃណី ល្បែងជាដើមមកពណ៌នា ។ ទាំងអស់នេះបញ្ជាក់អោយឃើញរាល់ថ្ងៃនូវទស្សនៈសង្គមខ្មែរ ផ្នត់គំនិតខ្មែរ ទំនៀមទំលាប់ខ្មែរ សិល្បៈខ្មែរ និង សមិទ្ធិផលផ្សេងៗ ដែលកើតចេញពីគំនិតខ្មែរ ។ គេធ្លាប់និយាយថា បើអ្នកធ្វើដំណើរទៅប្រទេសបារាំង អ្នកត្រូវស្គាល់វប្បធម៌បារាំងជាមុនសិន ។ ពីព្រោះអ្វី ? ពីព្រោះតែរឿងវប្បធម៌ខុសប្លែកគ្នានេះឯង ។ គេចាប់ដៃគ្នានៅពេលជួបគ្នា ដើម្បីសំដែងការគួរសម គេអោបគ្នា ថើបគ្នា ។ល ។ ខ្មែរយើងវិញ យើងត្រូវលើកដៃសំពះ ។ គេមិនអោបរឹតថើបគ្នាទេ ។ ដូច្នេះ វប្បធម៌ជាតិ សាសន៍ មានផ្សេងៗគ្នា ដូចជាវប្បធម៌ចិន ជប៉ុន ឥណ្ឌា អឺរ៉ុប ។ល ។ ជាតិសាសន៍ទាំងនោះ មានចិត្តថ្លើម គំនិត និង អាកប្បកិរិយា ប្លែកៗគ្នាទៅតាមវប្បធម៌របស់គេ ។

រីឯព្រលឹងវិញមានន័យថា ‹‹ ដំណើរជីវិត ស្មារតី វិញ្ញាណ សិរីសួស្ដី សេចក្ដីសុខ សេចក្ដីចំរើន ›› « វចនានុក្រមសម្ដេចព្រះសង្ឃរាជ **ជួន ណាត** » ។ ខ្មែរយើង កាលណាមនុស្សម្នាក់ភ័យខ្លាំង ហើយសន្លប់បាត់ស្មារតី គេតែងតែពោលថា មុនុស្សនោះបាត់ព្រលឹង រឺ លស់ព្រលឹង ។ គេនាំគ្នាធ្វើពិធីហៅព្រលឹងមកវិញ ដោយយកឈ្នាងជញ្ជាត់តាមគុម្ពចេក គុម្ពផ្កា ព្រោះគេយល់ថា ព្រលឹងរត់ទៅពួននៅទីនោះ ។

ដូចនេះ ឃ្លាថា វប្បធម៌ជាព្រលឹងរបស់ជាតិ បានសេចក្ដីថា ជាតិខ្មែរ រឺ ប្រជាជាតិខ្មែរជាតួខ្លួនមនុស្ស ។ រីឯវប្បធម៌ជាព្រលឹង ។ មានពាក្យមួយឃ្លាទៀតពោលថា ‹‹ វប្បធម៌រលំ ជាតិរលាយ ›› ។ ដូច្នេះយើងយល់ថា ជាតិនិងវប្បធម៌ជាតួអង្គ រឺ បុគ្គលតែមួយ ។

សំនួរបានលើកឡើងចង់ដឹងថា វប្បធម៌ ដែលមានជាអាទិ៍ សិល្បៈ អក្សរសាស្ត្រនេះ ម្ដេចក៏គេចាត់ទុកជាព្រលឹងវិញ្ញាណ ។ ដើម្បីដោះបំភ្លឺអោយកាន់តែច្បាស់នូវសំនួរខាងលើនេះ យើងខ្ញុំសូមលើកយកឧទាហរណ៍ ដើម្បីដាស់ចិត្ត

គំនិតអោយភ្ញាក់រលឹកឡើង ។

នៅពេលយប់ស្ងាត់ នៅស្រុកស្រែ ចំការ គេតែងឮស្គរសំលេងស្គរអារក្ស រឺ សំលេងខ្លុយ រឺ ទ្រ តើយើងជនជាតិខ្មែរ មានចិត្តរំភើបញ្ជាប់ញ៉ែរនឹកឃើញអ្វីទេ ? ប្រជាជនខ្មែរដែលសព្វថ្ងៃរស់នៅឯបរទេស ទោះជាប្រទេសនោះសម្បូរសប្បាយយ៉ាងណាក៏ដោយ ក៏នឹកមកប្រទេសជាតិខ្លួន ហាក់បីដូចជាមានអ្វីទាញចិត្តអោយនឹកឃើញអនុស្សាវរីយ៍ទាំងឡាយ ដែលខ្លួនធ្លាប់បានឃើញ ធ្លាប់បានធ្វើ ធ្លាប់បានសប្បាយ រឺ កើតទុក្ខ ។ គេនឹកស្រុក គេទិញកាសែតចំរៀងភ្លេងបុរាណ ភ្លេងសម័យ ទៅចាក់ស្តាប់ ។ សួរថា ភ្លេងចំរៀងនោះមានវិញ្ញាណ រឺទេ ? ហេតុអ្វីក៏គេនឹកស្រណោះ និង រំភើបខ្លាំង មានដល់ស្រក់ទឹកភ្នែកផង ។ ប្រសិនបើ មានគណៈប្រតិភូសិល្បៈខ្មែរទៅសំដែងនៅប្រទេសដែលខ្លួនរស់នៅនោះ គេនាំគ្នាទៅប្រជ្រៀតបែកញើស ហូរញើសបន្តទិញសំបុត្រចូលទស្សនា ។ នេះគឺព្រោះតែគេចង់ស្តាប់ភ្លេងចំរៀង ចង់ឃើញរបាំបុរាណ រឺ របាំប្រជាប្រិយ ។ល ។

ចំណែកឯជនបរទេស និង ជនជាតិខ្មែរ ដែលបានទៅទស្សនាប្រាសាទបុរាណខ្មែរ នៅខេត្តសៀមរាប រឺ ខេត្តដទៃ តែងតែពោលសរសើរបុព្វបុរសខ្មែរ ដែលមានបច្ចេកទេសខ្ពស់ បានសេចក្តីថា បុព្វបុរសខ្មែរចេះធ្វើថ្មឥតវិញ្ញាណអោយទៅជាមានព្រលឹង ហាក់ដូចជាថ្មចេះនិយាយ ចេះញញឹម ។ គេរំភើបចិត្ត ដោយឃើញភាពអស្ចារ្យនៃស្ថាបត្យកម្មនៃចំលាក់រូបព្រហ្មដែលញញឹមទៅរកទស្សនិកជន ទោះជាស្ថិតនៅកន្លែងមួយណាក៏ដោយ ‹‹ ប្រាសាទបាយ័ន ›› ។

ចំពោះអ្នកមានវិចារណញ្ញាណ គេឃើញរូបចំលាក់នោះ ស្នាដៃសាងសង់នោះមានតំលៃខ្ពស់ណាស់ គួរតែរក្សាទុកអោយបានគង់វង្ស ។ សព្វថ្ងៃនេះ ប្រាសាទខ្មែរទាំងប៉ុន្មានបានត្រូវចាត់ទុកជាសម្បត្តិមនុស្សជាតិ ដើម្បីអោយពិភពលោកជួយថែរក្សា ។ ផ្ទុយទៅវិញ មានមនុស្សមួយចំនួនតូច ដោយមានចិត្តលោភលន់ពន់ពេក មើលមិនឃើញភាពដ៏អស្ចារ្យនៃគំនិតអ្នកសាងសង់ គេហ៊ានកាត់ព្រះកេសព្រះពុទ្ធបដិមា ដឹកក្បាលយក្ស និង ទេវតាទៅលក់អោយជនបរទេស ឥតមានយល់ដឹងពីព្រលឹងជាតិ រឺ កេរមរតកជាតិបន្តិចសោះឡើយ ។

ចំពោះបញ្ហានេះ គួរក្រសួងអប់រំយុវជន និង កីឡា ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និង ក្រសួងអភិវឌ្ឍន៍សហគមន៍ រិះរកមធ្យោបាយដ៏ពិសិដ្ឋ ដើម្បីបំផុសគំនិតស្នេហាជាតិ ស្នេហាវប្បធម៌ជាតិ ដែលជាកេរមរតករបស់បុព្វបុរសខ្មែរ ។ មានតែមធ្យោបាយអប់រំបំផុសស្មារតីអោយយល់តំលៃវប្បធម៌តែមួយទេ ដែលយើងមានសង្ឃឹមថា នឹងទទួលបានលទ្ធផលល្អ ។ នៅចំពោះមុខបដិមាមួយ មនុស្សម្នាក់ហ៊ានគាស់រំលើង ហ៊ានអារបំបែក ។ ម្នាក់ទៀត ដោយមានឧត្តមគតិខ្ពស់មិនហ៊ានលូកដៃយកបដិមានេះទេ ។ យើងចង់បានមនុស្សមានហិរិឱត្តប្បៈ[(១)] មានមនសិការជាតិ ស្រឡាញ់ជាតិឯងពិតប្រាកដ ។

មធ្យោបាយដ៏មានប្រសិទ្ធភាព អាចមានសង្ឃឹមទៅអនាគតបាន គឺរាជរដ្ឋាភិបាលដែលមានក្រសួងអប់រំយុវជន និង កីឡាជាអ្នកទទួលខុសត្រូវ ត្រូវរៀបចំផែនការអប់រំប្រជាពលរដ្ឋទូទាំងប្រទេសតាមរយៈការបង្រៀនអក្សរសាស្ត្រ ការបង្រៀនភូមិវិទ្យា ប្រវត្តិវិទ្យា ពលរដ្ឋវិទ្យា និង វប្បធម៌ អរិយធម៌ ។ មេរៀនទីមួយៗ មានគោលដៅផ្សេងៗ គ្នាក៏ពិតមែន ក៏ប៉ុន្តែរួមមកមានគោលបំណងធំគឺ អប់រំមនុស្សគ្រប់វ័យអោយមានគុណធម៌ដ៏ប្រសើរបំផុត គឺសេចក្តីស្មោះត្រង់ចំពោះជាតិ ស្រឡាញ់ជាតិមាតុភូមិ ។ គ្រឹះដ៏មាំទាំងបួននេះ អាចទប់ខ្លួនគេកុំអោយងាករេទៅតាមខ្យល់ព្យុះបាន គឺ ទោសៈ មោហៈ លោភៈ ។ ដើមឈើ កាលណាមានឫសដុះជ្រៅទៅក្នុងដីហើយ មិនរង្គោះរង្គើបានដោយងាយឡើយ ។ មនុស្សក៏ដូច្នេះ

(១) - សេចក្តីខ្មាស់ បាប នឹកខ្លាចបាប ។ បាប បានសេចក្តីថា អំពើលាមក អាក្រក់ពុំប្រសើរ ។

ដែរ កាលណាគេស្រឡាញ់ទឹកដីរបស់គេដោយសេចក្ដីស្នេហាភ្ញាក់ស្វាង មិនមែនស្នេហាដោយងងឹតងងុល ខ្វះវិចារណញ្ញាណ ខ្វះការពិចារណា រកហេតុផលនោះឡើយ ។ អ្នក ១៧ មេសា ១៩៧៥ បានជ្រួតជ្រាបសព្វគ្រប់អស់ហើយ យើងមិនលាតត្រដាងទៀតទេ ។ គេបំផ្លាញជាតិ ប៉ុន្តែគេតាំងខ្លួនជាអ្នកស្នេហាជាតិទៅវិញ ។

ចំពោះមេរៀនទាំងបួននេះ តើក្រសួងទាំងបីនឹងអនុវត្តកម្មវិធី រឺ ផែនការតាមរូបមន្តណា ខ្ញុំសូមសាកល្បងស្នើការដោះស្រាយដូចតទៅ :

ទី១- ត្រូវបណ្ដុះបណ្ដាលឃោសនិកអោយយល់ច្បាស់ពីខ្លឹមសារមេរៀនទាំងបួន ។ ចុះនរណាជាឃោសនិក ?

ក- នៅក្នុងស្ថាប័នសិក្សាអប់រំ គឺគ្រូបង្រៀន

ខ- នៅក្រៅសាលារៀន គឺព្រះសង្ឃដែលមានប្រជាប្រិយភាព អ្នកមុខ អ្នកការនៅក្នុងភូមិ ឃុំ ស្រុក និងមន្ត្រីរាជការមានចរិយាធម៌ត្រឹមត្រូវ និងស្អាតស្អំ

គ- នៅក្នុងអង្គភាពនគរបាល និង កងខេមរភូមិន្ទ គឺអស់លោក ឧត្ដមសេនីយ៍ ដែលមានឥទ្ធិពលទៅលើកងទ័ព មានវោហារ តវ៉ុកោសល្យអោយគេចង់ស្ដាប់ ។

ទី២- ការផ្ដល់ហិរញ្ញវត្ថុ ដើម្បីផ្គត់ផ្គង់នូវការប្រព្រឹត្តទៅនៃគំរោង

ទី៣- រៀបចំ និង បោះពុម្ពឯកសារ សំរាប់សិស្ស អ្នករាជការ និង ប្រជាពលរដ្ឋ ។

ចំនុចទាំង ៣នេះ ទាមទារអោយមានការរៀបចំ ការគ្រប់គ្រង និងថវិកា ។

តើយើងអាចសង្ឃឹមថានឹងមានដំណើរការទៅមុខ រឺទេ ? យើងខ្ញុំជាអ្នកអប់រំ ដែលមានគំនិតបែបនេះ ប្រាថ្នាចង់អោយប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់មានអត្តសញ្ញាណជាតិ ពីព្រោះគេគ្រាន់តែឮពំនោលនៃអ្នកនយោបាយ តែនៅស្រពិចស្រពិលនៅឡើយចំពោះន័យនៃពាក្យនេះ ។

យុវជន យុវនារីខ្មែរ ដែលសព្វថ្ងៃកំពុងវង្វេងទិស មិនទាន់យល់ច្បាស់នូវអ្វីទៅដែលហៅថា អត្តសញ្ញាណជាតិ និង ព្រលឹងជាតិនោះ មុខជាមិនដឹងដើរទៅទិសណា ? ម្យ៉ាងទៀតគេតែងពោលថា យុវជន យុវនារី ជាទំពាំងស្នងឫស្សី រឺជាសសរទ្រូងនៃប្រជាជាតិទៅអនាគត ។ យើងនាំគ្នាសាកល្បងពិចារណាមើលពំនោលនេះ តើទំពាំងអាចលូតលាស់ល្អ និងត្រង់ដោយសារអ្វី ? នៅពេលភ្លៀងធ្លាក់ដើមឆ្នាំ ទំពាំងចាប់ដុះផុសចេញពីដី ។ ទំពាំង រឺពន្លកឫស្សីលូតលាស់ធំធាត់ល្អ ត្រង់ទាល់តែឫស្សីចាស់នៅជុំវិញមានភាពរឹងប៉ឹងជួយការពារកុំអោយខ្យល់បោកបក់ខ្លាំង ។ ទំពាំងដែលក្លាយទៅជាឫស្សីទើបស្នង ‹‹ ជំនួស ›› ឫស្សីចាស់ដែលត្រូវបានម្ចាស់គុម្ពឫស្សីកាប់យកទៅប្រើប្រាស់ជាបន្តបន្ទាប់ ។ ក្នុងសង្គមមនុស្ស ក៏ដូចនោះដែរ មនុស្សពេញវ័យដែលចាត់ទុកជាឫស្សីចាស់ គឺ ឪពុក ម្ដាយ គ្រូបាធ្យាយ ត្រូវអប់រំចិញ្ចឹមបីបាច់កូនចៅ ‹‹ ទំពាំង ›› អោយប្រកបនូវសីលធម៌ និង គុណធម៌ ព្រមទាំងចំណេះដឹងគ្រប់បែបយ៉ាង ទើបកូនចៅជំនាន់ក្រោយអាចស្នងអ្នកជំនាន់មុនបាន ។ បើមិនដូច្នេះទេ សង្គមកម្ពុជានឹងរលំរលាយជាមិនខាន ដូចគុម្ពឫស្សីកាលរបបសម័យពុល្បយាត ។ មនុស្សពេញវ័យគ្រប់ជំនាន់ត្រូវដឹងថា តើយើងមានកាតព្វកិច្ចអ្វីខ្លះ ដែលត្រូវបំពេញចំពោះជាតិមាតុភូមិ ។ កូនប្រុស កូនស្រី ដែលកើតចេញពីសាច់ឈាមរបស់ខ្លួនហើយ ឪពុក ម្ដាយត្រូវមាន :

១- កាតព្វកិច្ចចិញ្ចឹមបីបាច់ថែទាំ កុំបណ្ដោយអោយកូនរត់លេងស្រាតទទេល ដើរចាប់ក្ដាម ខ្យងនៅតាមវាលស្រែ កណ្ដាលថ្ងៃត្រង់ កណ្ដាលភ្លៀង ដោយមិនគិតពីអនាម័យ សុខភាពកូនបន្តិចសោះ ។

២- កាតព្វកិច្ចអប់រំ ប្រៀនប្រដៅអោយមានទំលាប់ល្អ ឫកពារអាកប្បកិរិយាត្រឹមត្រូវ ស្របទៅតាមបែបសីលធម៌សង្គម ។

យើងទាំងអស់គ្នា ដែលជាអ្នកគិតចំពោះវាសនាជាតិ ត្រូវចងចាំថា ទំពាំងអាចស្នងឫស្សីបានលុះត្រាតែទំពាំងនោះ ដុះមកហើយមានឫស្សីចាស់ជួយគាំពារ ។ បើមិនដូច្នេះទេ ទំពាំងនឹងបាក់កណ្ដាលដើម ប្រើការលែងកើត ។ សសរទ្រូងរឹងមាំទប់ទល់ទ្រទ្រង់ផ្ទះ មិនអោយរលំបាក់ លុះត្រាតែសសរនោះចេញពីពួកដើមឈើរឹងស្វិត ដូចជា ធ្នឹក សុក្រំជាដើម ។

ឱគួរអោយអាណិតអាសូរសង្គមខ្មែរបច្ចុប្បន្ន ឪពុកម្ដាយភាគតិចណាស់ដែលយកចិត្តទុកដាក់ទូន្មានកូន ។ សាលារៀនក៏ទប់ នឹង វិបត្តិសង្គមមិនឈ្នះ ។ បរិដ្ឋានសង្គមធ្លាក់ចុះ ទន្ទឹមគ្នា និង បរិដ្ឋានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ចំពោះបញ្ហាស្មាប់រស់នេះ យើងខ្ញុំយល់ឃើញថា អាទិភាពទី ១ គឺ អប់រំយុវជន យុវនារី អោយគេភ្ញាក់រលឹកនឹកឃើញ និង យល់ច្បាស់ពីអត្តសញ្ញាណជាតិ តាមរយៈមេរៀនទាំងបួនដែលបានគ្រោងមកហើយ ។ ទង្វើនេះនាំអោយគេ :

១- រកឃើញមកវិញនូវគ្រឹះដ៏រឹងមាំ គឺ ឯកភាពជាតិ

២- រកឃើញថាមវន្ត ដែលជាកំលាំងចាំបាច់ក្នុងស្ដាបនាប្រទេសជាតិឡើងវិញ ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមលើកយកពាក្យអត្តសញ្ញាណជាតិមកបំភ្លឺអោយបានយល់ជ្រួតជ្រាបទាំងអស់គ្នា ។ វចនានុក្រមព្រះសង្ឃរាជ **ជួន ណាត** បានប្រាប់ថា :

- អត្ត « បាលី » « អាត្ម័ន » ប្រែថា ខ្លួន - ចិត្ត

- សញ្ញាណ សេចក្ដីដឹងជាក់ ការយល់ច្បាស់ សេចក្ដីចូលចិត្តស៊ប់ - គ្រឿងសំគាល់ជាតិ connaissance, perception

ជាតិ រឺ ប្រជាជាតិ : ជាតិនៃមនុស្សដែលមានវង្សត្រកូល និង ភាសាជាមួយគ្នា ។ notion

តាមនិយមន័យខាងលើនេះ យើងខ្ញុំបែងចែកន័យអត្តសញ្ញាណជាតិ ជាពីរផ្នែក ។

**១- គ្រឿងសំគាល់ :**

បុរស ស្ត្រីគ្រប់រូប ត្រូវមានប័ណ្ណសំគាល់ខ្លួន ហៅថា អត្តសញ្ញាណប័ណ្ណ ។ ក្នុងប័ណ្ណនេះភ្ជាក់ងារទទួលបន្ទុកកត់គ្រប់លក្ខណៈសំគាល់នៃជនម្នាក់ៗ ដូចជា អាយុ កំពស់ មុខរបរ អាស័យដ្ឋាន ព្រមទាំងតិនភាគផ្សេងៗ ទៀត ដូចជា ពណ៌សម្បុរ ប្រជ្រុយ ចិញ្ចើម និង ក្រយៅម្រាមដៃទាំងដប់ ។

ចំពោះសត្វ គោ ក្របី ពេទ្យសត្វ ក៏ធ្វើអត្តសញ្ញាណប័ណ្ណអោយវាដែរ ដែលអាចសំគាល់វាបានឥតច្រលំ ។

**២- ការជឿជាក់ រឺ ជំនឿស៊ប់ :**

ដូចនេះ **អត្តសញ្ញាណជាតិ** គឺ ការជឿជាក់នៃបុគ្គលម្នាក់ៗ ថាខ្លួនរស់នៅក្នុងសហគមន៍មួយដែលជាទូទៅ មានភាសា និង វប្បធម៌មួយដូចគ្នា *រស់នៅលើទឹកដីជាមួយគ្នា មានអតីតកាលដូចគ្នា* មានមនោសញ្ចេតនា និង ឆន្ទៈរួមគ្នា ដែលបង្កើតបានជាចរិតមួយដូចគ្នា ។

យើងសង្ឃឹមថា អត្តសញ្ញាណជាតិ នឹងមកស្ថិតនៅលើចិត្តគំនិត នៃពលរដ្ឋខ្មែរគ្រប់រូប នឹងជាកំលាំងចលករបំផុសនូវមនសិការជាតិ និង មនោសញ្ចេតនាស្នេហាកេរមរតករបស់បុព្វបុរស ដែលបានទុកអោយកូនចៅជំនាន់ក្រោយ ។

គួរណាស់តែយើងដឹងគុណ និង ប្ដេជ្ញាចិត្តជួយថែរក្សាកេរមរតកអោយបានគង់វង្សតទៅទៀត ។

គណៈកម្មាធិការកណ្ដាល

# សមាសភាគនៃការអប់រំ

នៅក្នុងសេចក្តីប្រកាសជាសាកលអំពីសិទ្ធិមនុស្សកាលពីថ្ងៃទី ១០ ធ្នូ ១៩៤៨ នៅអង្គការសហប្រជាជាតិ មាត្រា ២៦ បានចែងថា ការអប់រំត្រូវតំរង់ទិសឆ្ពោះទៅរកការលូតលាស់យ៉ាងពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស ( l'éducation doit viser au plein épanouissement de la personnalité humaine . . . )

តើការធ្វើអោយរីក រឺ អោយលូតលាស់បុគ្គលិកលក្ខណៈរបស់មនុស្ស (Epanouir la personnalité humaine) មានន័យដូចម្តេច ? អ្វីទៅដែលហៅថា បុគ្គលិកលក្ខណៈរបស់មនុស្ស ? ។ ចំពោះពាក្យទាំងប៉ុន្មានខាងលើ ខ្ញុំជឿជាក់ថា លោកគ្រូ អ្នកគ្រូបានលឺ និងបានទន្ទេញចាំមាត់ថែមទៀតផងកាលនៅជាគរុសិស្សនៃសាលាគរុកោសល្យ ។ ប៉ុន្តែការយល់អោយបានស៊ីជំរៅ ខ្ញុំអាចសន្និដ្ឋានថា មានខ្លះមិនទាន់ជាក់ច្បាស់នៅឡើយទេ ។ លោកអ្នកអប់រំខ្លះចេះប្រើពាក្យថា គោរពបុគ្គលិកលក្ខណៈកុមារ ( respecter la personnalité de l'enfant ) ។ ដូចនេះបុគ្គលិកលក្ខណៈដែលនិយាយក្នុងចិត្តគរុកោសល្យមានន័យយ៉ាងណា ? ចំពោះភារកិច្ចដែលធ្វើអោយរីក រឺ លូតលាស់នោះ តើត្រូវធ្វើដូចម្តេចទើបបានរីកអោយអស់ ហើយអោយល្អផងនោះ ( épanouissement intégral et harmonieux )

បុគ្គលិកលក្ខណៈ ‹‹ បុគ្គលិក - លក្ខណៈ ›› តាមន័យក្នុងវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត បានអោយដឹងដូចតទៅ : ‹‹ លក្ខណៈរបស់បុគ្គលម្នាក់ៗ លក្ខណៈ រឺគ្រឿងកំណត់ចំណាំរបស់បុគ្គល ។ លក្ខណៈជាគ្រឿងសំគាល់ចំពោះមនុស្ស រឺ សត្វ ›› ។ និយមន័យនេះ ជានិយមន័យទូទៅ កាលណាយើងនិយាយពីបុគ្គលិកលក្ខណៈ គឺយើងតំរង់ រឺ ផ្តោតទៅលើលក្ខណៈរបស់បុគ្គល រឺ មនុស្ស ។ រីឯសត្វវាមានលក្ខណៈចំនាំតែខាងក្រៅទេ ។

ក្នុងការអធិប្បាយតទៅមុខទៀតនេះ ខ្ញុំសូមអនុញ្ញាតប្រើពាក្យបុគ្គលផង មនុស្សផង ។

មនុស្សយើងគ្រប់រូបទាំងប្រុស ទាំងស្រី ចាប់តាំងពីកើតមកមានភិន្នភាគខាងក្រៅមិនដូចគ្នាឡើយ ទោះជាបុរសរឺនារីទោះជាកូនភ្លោះក៏ដោយ ។ គេក៏អាចចំណាំបានថា នេះឈ្មោះ ក ជាបង នេះឈ្មោះ ខ ជាប្អូន ។ សូមជំរាបថា មនុស្សមានតួខ្លួនជាចន្ទល់ រឺជាជំរកនៃលក្ខណៈចិត្ត ( psychisme ) ។

ដូចនេះ បុគ្គលិកលក្ខណៈជាកន្សោម ( ensemble ) នៃចរិតលក្ខណៈដែលខុសប្លែកគ្នាពីជនម្នាក់ទៅជនម្នាក់ទៀតជាមនុស្សដូចគ្នា ។ តើខុសប្លែកគ្នាត្រង់ណា ? គឺ : រូបរាងកាយ បុកពារ ចរិត បញ្ញា ជាដើម ។

ដើម្បីពង្រីកបុគ្គលិកលក្ខណៈរបស់កុមារ ( épanouir la personnalité de l' enfant ) ជាដំបូងគេត្រូវស្គាល់ពីស្ថានភាពសិស្សនេះសិនថាតើវាមានលទ្ធភាពធ្វើអ្វីបាន មានបញ្ញា រឺទេ ? កាយសម្បទាវាយ៉ាងដូម្តេច ? ចរិតតំនពូជវាលេចចេញអោយឃើញយ៉ាងណា ?

ឪពុកម្តាយអ្នកអប់រំ លុះពិនិត្យឃើញដូច្នេះហើយត្រូវធ្វើការអប់រំដើម្បីពង្រីកគុណសម្បត្តិរបស់វា និងធ្វើការកែលំអគុណវិបត្តិ ។ ធ្វើយ៉ាងនេះបានលុះតែគ្រូប៉ិនប្រសប់ប្រើវិធីគរុកោសល្យរបៀបណាអោយសិស្សមានសេរីភាពបញ្ចេញអោយអស់នូវចរិតរបស់វា ត្រង់នេះហើយដែលខ្ញុំបានជំរាបថា គ្រូត្រូវគោរពបុគ្គលិកលក្ខណៈកុមារដើម្បីធ្វើអោយបុកពារចរិយាវាលេចចេញឡើង ។ ចរិតលក្ខណៈណាល្អត្រូវពង្រីក រឺ បណ្តុះបណ្តាលអោយដុះដាលល្អ ។ ចរិតលក្ខណៈមិនល្អត្រូវកែលំអតាមវិធីគរុកោសល្យ ។

តាមសេចក្ដីដូចរៀបរាប់មកខាងលើ គេរំឭកប្រដូចបុគ្គលិកលក្ខណៈទៅនឹងផ្កា ដែលធម្មជាតិបង្ហាញអោយឃើញថាមុននឹងបានជាផ្ការីកពេញទំហឹងនោះ មុនដំបូងវាជាពន្លក ។ យូរបន្តិចមកពន្លកនេះឡើងក្រពុំទើបរីកជាផ្កា ។ បុគ្គលិកលក្ខណៈក៏ដូច្នេះដែរ វាកកើតបន្តិចម្ដងៗ ហើយរស់នៅក្នុងមជ្ឈដ្ឋានដំបូង គឺគ្រួសារ បន្ទាប់មក គឺសាលារៀន និងបន្ទាប់មកទៀត គឺសង្គម ។

បុគ្គលិកលក្ខណៈ ដែលអ្នកអប់រំមានភារកិច្ចបណ្ដុះបណ្ដាល គឺផ្ដោតទៅលើបុគ្គលិកលក្ខណៈសីលធម៌ ( personnalité morale ) ។ និយាយមួយបែបទៀតថា សង្គមចង់បានមនុស្សប្រកបដោយសីលធម៌ គឺមនុស្សមានសមត្ថភាព និងស្មារតីបង្កើតជាមួយអ្នកដទៃនូវទំនាក់ទំនងជាគុណប្រយោជន៍ដល់ការរស់នៅមានសុភមង្គល ។ បុគ្គលដែលខ្សោយគ្មានកំលាំងកំហែង គ្មានឆន្ទៈ គេមិនអោយឈ្មោះថា មនុស្សមានបុគ្គលិកលក្ខណៈទេ ។ ដូចគ្នានឹងអត្តទត្ថបុគ្គលដែលគិតតែអាត្មាអញ រឺ បុគ្គលជាមនុស្សខូច រឺ ប្រព្រឹត្តបទអាក្រក់ ដូចជាចោរលួច ចោរប្លន់ កាប់សំលាប់គេដើម្បីដណ្ដើមយកទ្រព្យសម្បត្តិមកធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួន ។

សូមជំរាបបន្ថែមទៀតថា ពាក្យបុគ្គលិកលក្ខណៈមានន័យប្លែកៗ គ្នាទៅតាមកម្មវត្ថុសិក្សាស្រាវជ្រាវដូចជា ក្នុងទស្សនវិជ្ជា សង្គមវិទ្យា សីលធម៌ សោភ័ណវិទ្យា ។ល ។ នៅពេលនេះយើងសិក្សាពីបុគ្គលិកលក្ខណៈតែក្នុងចិត្តគរុកោសល្យប៉ុណ្ណោះ ។

ដើម្បីបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈអោយបានរីកល្អ និងអោយបានពេញលេញ សមាសភាគទាំង ៥ នៃការអប់រំដែលសាលារៀនយើងបានអនុវត្តមកហើយនោះ ជាកំលាំងចលករជំរុញអោយការអប់រំបុគ្គលិកលក្ខណៈរីកចំរើនគ្រប់ជ្រុងជ្រោយស្របទៅតាមទិសដៅនៃការអប់រំ ។

**១- ការអប់រំកាយ :**

គឺធ្វើអោយកាយមានសុខភាពទាំងពីរប្រការ គឺសុខភាពកាយ ( santé physique ) និង សុខភាពចិត្ត រឺ ស្មារតី ( santé mentale ) ។ ពាក្យស្លោកមួយឃ្លានិយាយថា ‹‹ គំនិតល្អភ្លឺថ្លា ស្ថិតនៅក្នុងកាយមានសុខភាពបរិបូណ៌ ( une âme saine dans un corps sain ) ។

ចំពោះបញ្ហានេះ អ្នកអប់រំកាយ និងកីឡាបានជ្រួតជ្រាបអស់ហើយពីផលប្រយោជន៍នៃការអប់រំកាយ ។ ម្យ៉ាងទៀតគាត់បានសិក្សាពីសរីរវិទ្យា ( physiologie ) ដែលនាំអោយយល់ពីមុខងារនៃសរីរាង្គនិមួយៗ ។ គាត់ដឹងថា សិស្សនេះខ្ជិល តើមកពីមូលហេតុអ្វី ? ដូចគ្នានឹងសិស្សតក់មិកល្ហើយមិនបានលើកដៃជើង ។

ដើម្បីបង្កើនសុខភាពកាយ និង ស្មារតី សិស្សក្នុងវ័យកំពុងលូតលាស់ត្រូវការការឧបត្ថម្ភពីលោកគ្រូពេទ្យ ។ វាខ្វះអ្វី ? បានជាវាលូតលាស់យឺត ។

ការហាត់ប្រាណ និង កីឡានៅតាមសាលា គួរធ្វើអោយបានទៀងទាត់ ហើយប្រកបដោយប្រសិទ្ធភាពផង ។

អត្តពលិក និង កីឡាករ តាមរយៈការហាត់ និង ការប្រកួត គេមានស្មាតីប្រយុទ្ធ មានការអំណត់អត់ធន់មានសេចក្ដីក្លាហាន ។ នេះហើយលក្ខណៈសម្បត្តិដ៏ប្រសើរសំរាប់មនុស្សគ្រប់រូបក្នុងការប្រកបការងារការពារខ្លួន ការពារមាតុភូមិ ។

**២- ការអប់រំបញ្ញា**

អ្វីទៅដែលហៅថា បញ្ញា រឺ ប្រាជ្ញា ? បញ្ញាតាមន័យក្នុងវចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ

**ជួន ណាត** ប្រែថា ‹‹ សេចក្ដីដឹងទូទៅ សេចក្ដីដឹងកើតអំពីការរៀនស្ដាប់ គិត សួរ ការដឹងច្បាស់នូវសេចក្ដីពិត ›› ។

ខ្ញុំសូមជំរាបថា ក្នុងការអប់រំបញ្ញាត្រូវរួមផ្សំការដឹង និងការយល់ ។ ការអប់រំបញ្ញាគឺ ការពង្រីកមុខងារ ( fonction ) ដែលនាំអោយដឹង អោយយល់គឺ ការសង្កេត ការចំណាំ ជាពិសេសការវិនិច្ឆ័យ គំនិតវែកញែករកខុសត្រូវ គំនិតត្រឹមត្រូវតាមតក្កវិជ្ជា ។

លោកគ្រូអ្នកគ្រូ បានផ្ដល់ចំណេះដឹងអោយសិស្សតាមរយៈការបង្រៀន ( enseignement ) និងការរៀនរបស់សិស្ស ។ ដោយការប៉ិនប្រសប់របស់លោកគ្រូអ្នកគ្រូ សិស្សបានយល់ ។ សិស្សចេះត្រិះរិះពិចារណា និងមានគំនិតច្នៃប្រតិដ្ឋ[1] ។ ដើម្បីបញ្ជាក់នូវការយល់នេះ លោកគ្រូអ្នកគ្រូចោទសំនួរប្រាជ្ញាដើម្បីអោយសិស្សគិត រឺដាក់លំហាត់ដោយចង់បញ្ជាក់ការយល់របស់សិស្ស ។ លំហាត់នេះហើយជាខ្លឹម និងជាគោលដៅនៃការអប់រំបញ្ញា ។ បញ្ញាដុះលូតលាស់បានល្អដោយសារសំនួរប្រាជ្ញា និងលំហាត់ ។ លំហាត់កាន់តែច្រើនកាលណា បញ្ញាកាន់តែខ្លាំង ។

ការបង្រៀនមិនបានគោរពគោលការណ៍អប់រំ និងវិធីសាស្ត្រគរុកោសល្យចាត់ទុកជាអំពើមួយខ្វះមនសិការ ។ លោកគ្រូអ្នកគ្រូផ្ដល់ចំណេះដឹងអោយសិស្ស ដោយមិនបានបំផុសអោយយល់ដឹងពីខ្លឹមសារនៃមេរៀន គឺជាការបញ្ចុកចំណីអាហារនាំអោយតែណែនខួរក្បាល នាំតែខាតកំលាំង និងពេលវេលាឥតប្រយោជន៍ ។ គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានគោលបំណងប្លែកគ្នា តែរួមមកមានបី គឺ ១- ផ្ដល់ពុទ្ធិ ២- អនុវត្តន៍ រឺ សមត្ថភាព រឺ បំនិនប្រសប់ក្នុងការងារ ៣- ការបណ្ដុះចិត្តគំនិត អត្តចរិត និង ឥរិយាបទជាមនុស្សល្អ ពលរដ្ឋល្អ ពលករល្អ ។

សិស្សទាញចេញពីពុទ្ធិ រឺចំណេះដឹងនូវរូបារម្មណ៍ ( imagination ) ការវិនិច្ឆ័យ ( jugement ) វិចារណកិច្ច ( raisonnement ) ។ ដូច្នេះ គួរលោកគ្រូអ្នកគ្រូពិចារណាឡើងវិញដើម្បីលើកកំពស់គុណភាពអប់រំ ។ គួរសួរខ្លួនឯងថា គោលបំណងនៃការបង្រៀនគណិតវិទ្យា រូបវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា ពលរដ្ឋវិទ្យា ។ល ។ នៅត្រង់ណា? តើមធ្យោបាយដែលដើរឆ្ពោះទៅដល់គោលដៅត្រូវធ្វើដូចម្ដេច ?

ម្យ៉ាងទៀត ការអប់រំបញ្ញានៅសាលាចំណេះទូទៅទាមទារការប៉ិនប្រសប់ និងឆន្ទៈមុតស្រួចរបស់លោកគ្រូអ្នកគ្រូដែលពលីកំលាំងកាយ ចិត្ត ចំពោះបុព្វហេតុអប់រំយុវជនជំនាន់ក្រោយអោយមានចំណេះដឹង ‹‹ វប្បធម៌ ›› សមស្របទៅតាមការវិវឌ្ឍវិទ្យាសាស្ត្រ និង សង្គម ព្រោះសព្វថ្ងៃនេះការវិវឌ្ឍលឿនណាស់ ។ ម្យ៉ាងទៀត គួរបំផុសគំនិតសិស្សានុសិស្សអោយចង់ចេះ ចង់ដឹងជាប្រចាំទៅអនាគត ព្រោះពិភពលោកទាំងមូលយល់ឃើញថា ការចេះដឹងពីសាលារៀនមិនទាន់គ្រប់គ្រាន់ជូនល្មមនៅឡើយទេ ពលករម្នាក់ៗ ត្រូវដើរអោយទាន់សភាពការណ៍វិវឌ្ឍនៃវិទ្យាសាស្ត្រ គឺត្រូវរៀនជាប្រចាំ ។

### ៣- ការអប់រំសីលធម៌ និង ពលរដ្ឋវិជ្ជា

#### *ក- សីលធម៌ :*

តាមនិយមន័យក្នុងវចនានុក្រមខ្មែររបស់សម្ដេច **ជួន ណាត** ប្រែថា ‹‹ ដំបូន្មានដែលនាំអោយចៀសវាងអំពើអាក្រក់ ហើយអោយប្រព្រឹត្តតែអំពើល្អ ›› ។

គួរយល់ម្យ៉ាងទៀតថា សីលធម៌គឺជាគន្លងមនោសញ្ចេតនា រឺ ក្បួនខ្នាតដែលមនុស្សត្រូវប្រតិបត្តិតាម ។

តាមនិយមន័យទាំងពីរនេះ យើងឃើញថា ទិសដៅនៃការអប់រំសីលធម៌ទោះក្នុងសាលារៀនក្ដី ក្នុងសង្គមក្ដី គឺសំដៅអប់រំមនុស្សអោយចេះរស់នៅក្នុងគ្រួសារ ក្នុងសមូហភាពប្រកបនូវសុខដុមរមនា រអុករអ៊ីនជាមួយគ្នា ចេះគួរសម

(១) - អានថា ប្រឌិត តាមវចនានុក្រម **ជ.ណ.** គួរសរសេរ ប្រតិដ្ឋ ( ត្រឹមត្រូវជាង )

ចេះអត់អោនគ្នា មិនឈ្នានីសគ្នា មិនតេងប្រវញ្ចគ្នា មិនគិតតែអាត្មាអញ និងគ្រួសារអញប៉ុណ្ណោះ ។

ការគោរពវិន័យសាលា គឺជាការហាត់ពត់លត់ដំមួយដើម្បីអោយសាលាមានសណ្ដាប់ធ្នាប់នៅពេលកំពុងរៀន ពេលចេញមកផ្ទះ និងពេលមុនចូលរៀន ។ ការអប់រំសិស្សបានល្អនៅក្នុងសាលានីមួយៗ ជាការសំដែងចេញពីឆន្ទៈ និងការគ្រប់គ្រងដ៏ប៉ិនប្រសប់នៃលោកនាយក និងសហការីដែលមានសាមគ្គីជាធ្លុងមួយ លើកតំកើងកិត្តិនាមរបស់សាលា ។

ម្យ៉ាងទៀត មុខងារគ្រូជាមុខងារទាមទារពលិកម្មគ្រប់នាទី ព្រោះភ្នែកអ្នកស្រុក ភូមិ និងសិស្សានុសិស្សចេះតែបាញ់មកមើលគ្រូ ។ គេមើលគ្រប់សកម្មភាពលោកគ្រូអ្នកគ្រូ ។ ដូចនេះគួរតែលោកគ្រូអ្នកគ្រូប្រុងប្រយ័ត្នកុំភ្លេចស្មារតី ហើយជៀសវាងកុំអនុវត្តពាក្យ ‹‹ ពុតគ្រូកុំប្រាប់ ច្បាប់គ្រូអោយយក ›› នៅចំពោះមុខសិស្ស និង ឪពុកម្ដាយសិស្ស ។ ម្យ៉ាងទៀត តួនាទីលោកគ្រូអ្នកគ្រូទាមទារគុណសម្បត្តិច្រើនណាស់ ។

*ខ- អប់រំពលរដ្ឋវិជ្ជា*

ពលរដ្ឋវិជ្ជា រឺ វិជ្ជាអប់រំពលរដ្ឋ ( éducation civique ) មានគោលបំណងធ្វើអោយសិស្សប្រុសស្រី ក្លាយជាសមាជិកនៃសង្គមមួយរួបមានសារប្រយោជន៍ចំពោះជាតិ ស្មោះត្រង់នឹងជាតិ ។

វិជ្ជានេះត្រូវបង្រៀនផង អប់រំផង ។ ចាប់ពីបឋមសិក្សា គ្រូបង្រៀនត្រូវអប់រំសិស្សអោយគោរពបទបញ្ជាផ្ទៃក្នុងសាលារៀន គោរពច្បាប់ចរាចរ ចេះថែរក្សាទ្រព្យសម្បត្តិរួមរបស់សាលា . . . ។ល ។ អោយដឹងពីការគ្រប់គ្រងរដ្ឋ និងស្គាល់ស្ថាប័នរដ្ឋពីថ្នាក់ឃុំ សង្កាត់ ខ័ណ្ឌ ស្រុក ខេត្ត-ក្រុង និងការបែងចែកអំណាចទាំងបី ។ល ។

រួមសេចក្ដីមក គឺអប់រំអោយចេះប្រើសិទ្ធិ និងសេរីភាពខ្លួន និងអោយដឹងពីករណីយកិច្ចរបស់ខ្លួន ។ ទន្ទឹមនឹងនេះអប់រំសិស្សអោយមានអត្តសញ្ញាណជាតិ មានមនសិការជាតិដើម្បីកសាង និងការពារជាតិខ្លួនអោយបានចំរើនរុងរឿង ។

## ៤- ការអប់រំពលកម្ម

ចាប់ពីឆ្នាំ ១៩៧៩ មក យើងប្រើពាក្យ ពលកម្ម នៅគ្រប់ទីកន្លែង ជាពិសេសនៅក្នុងសាលារៀន ។ ថ្ងៃព្រហស្បតិ៍ជាថ្ងៃសំរាក ហេតុអ្វីបានជាកូនឯងទៅសាលារៀន ( ឪពុកសួរ ) កូនឆ្លើយថា ខ្ញុំទៅធ្វើពលកម្ម ។ បានសេចក្ដីថា ខ្ញុំទៅធ្វើសួនបន្លែ ទៅសំអាតសាលា រឺ ថ្នាក់រៀន ។ល ។ ដូច្នេះ តាមពាក្យ ពលកម្ម គេនាំគ្នាយល់ថា ការងារធ្វើដោយដៃ រឺ ហត្ថកម្ម រឺ ហត្ថពលកម្មទៅវិញ ។ គួរប្រើពាក្យ ហត្ថពលកម្ម អោយស្របតាមពាក្យបារាំងថា (travail manuel) ព្រោះក្នុងសមាសភាគអប់រំនេះ គេសំដៅអប់រំដៃជាធំ ។ ការអប់រំបញ្ញា (éducation intellectuelle) យើងបានរៀបរាប់រួចមកខាងដើមហើយ បើនិយាយពីពលកម្ម យើងអាចនិយាយថា ពលកម្មដោយដៃ និង ពលកម្មដោយប្រាជ្ញា ។

ខ្ញុំគ្រាន់តែទាញអារម្មណ៍ប៉ុណ្ណោះ ដើម្បីសូមជួយពិចារណា ។ ក្នុងសមាសភាគនេះ យើងនាំគ្នាសិក្សាអំពីការអប់រំអោយមានការប៉ិនប្រសប់ក្នុងការប្រើដៃដូចគ្នា និងការប៉ិនប្រសប់ក្នុងការប្រើបញ្ញា រឺ ខួរក្បាល ។ តើការអប់រំហត្ថពលកម្មនេះមានទិសដៅយ៉ាងណា ? ខ្ញុំយល់ថា លោកគ្រូ អ្នកគ្រូមុខជាយល់ច្បាស់ពីខ្លឹមសារនៃហត្ថពលកម្ម ។ ខ្ញុំសូមបន្ថែមថា នៅលើពិភពលោកសព្វថ្ងៃ ការអប់រំហត្ថពលកម្មដើរទន្ទឹមគ្នានិងការអប់រំបញ្ញា រឺខួរក្បាល ព្រោះដៃនិងខួរក្បាលពិតមែនតែមានមុខងារខុសគ្នារៀងៗខ្លួន តែត្រូវមានការហាត់ពត់ដើម្បីអោយមានការប៉ិនប្រសប់ មានភាពរហ័សរហួន និងទន់ភ្លន់ ។

ការបង្កើតអោយមានហត្ថពលកម្ម រឺ ហត្ថកម្មនៅក្នុងសាលាតាំងពីថ្នាក់តូចដល់ថ្នាក់ធំ គឺមានគោលបំណងដូច

ខាងលើ ។ នៅសាលាមធ្យមសិក្សាភូមិ ១ និងភូមិ ២ យើងបង្កើតរោងជាង « សព្វថ្ងៃមិនទាន់មានគ្រប់សាលាទេ ដោយខ្វះគ្រូបច្ចេកទេស » ក្នុងគោលបំណងបង្ហាត់បង្រៀនសិស្សអោយចេះបត់ កាត់ លាប ចេះធ្វើសត្វពីដីឥដ្ឋ ចេះត្បាញក្រដាស រឺ ឫស្សី ចេះគូរ ចេះឆ្លាក់ ចេះត្បាញ ចេះធ្វើរូបសត្វពីស្នែងក្របី រឺ គោ ។ ចំពោះសិស្សថ្នាក់ធំ គ្រូរោងជាងបង្ហាត់អោយធ្វើកៅអី ជើងម៉ា ។ល ។

សាលារៀននៅទីរួមខេត្តក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ជារៀងរាល់ឆ្នាំ លោកអធិការបឋមសិក្សាតែងតែដឹកនាំអោយរៀបចំពិព័រណ៍សិក្សាដោយគ្រប់តំបន់អធិការកិច្ចនាំមកនូវរបស់របរជាច្រើនមកតាំង និងលក់យកកំរៃ ។ ការតាំងពិព័រណ៍នេះបង្កើតអោយមានស្មារតីប្រលងប្រណាំង ។ សិស្សដែលធ្វើអ្វីបានល្អ លក់ដាច់អស់នៅពេលបិទពិព័រណ៍ សប្បាយចិត្តណាស់ថែមទាំងបានប្រាក់កំរៃផង ។

## ៥- ការអប់រំសិល្បៈ រឺ សោភ័នភាព

គឺជាផ្នែកអប់រំមួយដែលបណ្តុះ និង ពង្រីកទឹកចិត្តស្រឡាញ់

ក- សោភ័នភាពដោយបង្រៀនប្រវត្តិសិល្បៈ និងបង្រៀនអោយសិស្សម្នាក់ៗ ចេះច្រៀង ចេះរាំ ចេះកាន់ឧបករណ៍ភ្លេងអ្វីមួយគ្រាន់តែជាសញ្ញាណ រឺគ្រាន់តែដាស់វិញ្ញាណអោយភ្ញាក់ ចេះគូរ ។ល ។

ខ- ប្រពៃណីល្អរបស់ប្រជាជន និងប្រទេសជាតិមានរបាំប្រពៃណី ចំលាក់ សំលៀកបំពាក់ជាដើម ។

សព្វថ្ងៃនេះ សាលារៀនយើងមួយចំនួន ជាពិសេសនៅទីរួមខេត្ត និងក្រុង បានបង្ហាត់អោយសិស្សចេះច្រៀង « ម្នាក់ឯង រឺ ជាពួក » ចេះលេងភ្លេង ចេះរាំ ។ល ។ នេះជាការប្រសើរតាមការសង្កេតរបស់ខ្ញុំ ។ ខ្ញុំឃើញថា គោលដៅដែលយើងចង់បានក្នុងសមាសភាគអប់រំនេះមិនទាន់ទៅដល់នៅឡើយទេ ។ តើអ្នកអប់រំមានគោលបំណងយ៉ាងណា ? គឺចាត់អោយបានចេះគ្រប់ៗគ្នា ចេះតិច រឺច្រើន ដើម្បីរាវរកអ្នកមានទេពកោសល្យទៅអនាគត ។ អ្នកជីវសាស្រ្ត និងអ្នកអប់រំមានមតិស្របគ្នាថា និស្ស័យដែលមានមកតាមតំណពូជ ប្រសិនបើនៅក្នុងមជ្ឈដ្ឋានអនុគ្រោះ នោះវាកាន់តែរីកចំរើនឡើង ។ ផ្ទុយទៅវិញ ប្រសិនបើនៅក្នុងមជ្ឈដ្ឋានចុងកាត់មាត់ញកដាច់ឆ្ងាយពីគេឯង នោះវាមិនចំរើនទេ ។ បានសេចក្តីថា កុមារណាមួយដែលមាននិស្ស័យខាងភ្លេងពីកំនើត តែរស់នៅដាច់ពីគេឯងមិនបានទទួលការអប់រំនិស្ស័យកុមារនោះ និងរៀវរួញខូចអសារ ។

អាស្រ័យហេតុនេះ គួរតែក្រសួងអប់រំបញ្ចូលសមាសភាគអប់រំនេះទៅក្នុងកម្មវិធីសិក្សា ។ រីឯអ្នកបង្ហាត់បង្រៀនក្រសួងនឹងរើសពីសាកលវិទ្យាល័យវិចិត្រសិល្បៈ ។

ម្យ៉ាងទៀត ការបង្រៀនគំនូរហាក់ដូចជាបោះបង់ចោលទាំងស្រុង ។ តើក្នុងកម្មវិធីសិក្សាមានមុខវិជ្ជានេះរឺទេ? លោកគ្រូអ្នកគ្រូក៏មិនបានបណ្តុះបណ្តាលខ្លួនឯងអោយបានជ្រៅជ្រះក្នុងវិជ្ជានេះ ព្រោះនៅសាលាគរុកោសល្យក៏មិនមានមុខវិជ្ជានេះដែរ ។ មុខវិជ្ជានេះក៏ដូចមុខវិជ្ជាភ្លេង ចំរៀងដែរ គឺមានទិសដៅរាវរកអ្នកមានកោសល្យ ( talent ) ។ រីឯគ្រូបង្រៀនសិល្បៈគំនូរនេះក៏អាចយកពីសាកលវិទ្យាល័យវិចិត្រសិល្បៈ រឺមួយក្រសួងអប់រំបើកថ្នាក់បណ្តុះបណ្តាលគ្រូគំនូរខ្លួនឯងតែម្តង ។ នេះជាការល្អប្រសើរ ។

ជាសរុប ការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈសិស្សនឹងមានប្រសិទ្ធភាព បើសាលារៀនអនុវត្តបានម៉ឺតចត់ត្រឹមត្រូវនូវសមាសភាគទាំង ៥ ដូចរៀបរាប់ខាងលើនេះ ។ យើងខ្ញុំសង្ឃឹមថា គុណភាពអប់រំត្រូវបានលើកកំពស់ជាមិនខានទៅអនាគត ។

ដោយលោក **យ៉ង់ ធី**

*




## បញ្ហាសិស្សឈប់ច្រើន និង រៀនមិនចប់កម្មវិធីសិក្សា

ដោយឃើញថាបញ្ហានេះមានសារៈសំខាន់ យើងសូមដកស្រង់យកសំនួរ - ចំលើយក្នុងការប្រជុំពិភាក្សាដោយផ្ទាល់របស់វគ្គវិក្រឹតការគ្រូបឋមសិក្សាខេត្តកណ្ដាលកាលពីខែ វិច្ឆិកា ១៩៩៣ មកផ្សព្វផ្សាយជូនលោកគ្រូ - អ្នកគ្រូ ជ្រាប និងជួយដោះស្រាយទៅតាមស្ថានភាពសាលារៀនរៀងៗ ខ្លួន និងតាមខេត្ត - ក្រុងនីមួយៗ ។

**សកម្មភាពប្រជុំពិភាក្សាដោយផ្ទាល់**

សំនួរដូចខាងក្រោមនេះត្រូវបានអោយគ្រូពិភាក្សាជាក្រុមតូចៗ ៖

### សំនួរ

១.ក. តើជំពូកសិស្សដែលឈប់ច្រើន មានលក្ខណៈដូចម្ដេចខ្លះ ?

ខ. តើគ្រូអាចជួយកែលំអបញ្ហាសិស្សឈប់ច្រើននេះដូចម្ដេចខ្លះ ?

**សំគាល់** : ក្នុងការពិភាក្សារកចំលើយលើបញ្ហានេះគ្រូបានកត់សំគាល់លើ

- ការងាររបស់គ្រូ
- បញ្ហាទំនាក់ទំនងរវាងសាលារៀន និងសហគមន៍

### ចំលើយ

**ជំពូកសិស្សដែលឈប់ច្រើនមានលក្ខណៈដូចខាងក្រោមនេះ ៖**

- ជីវភាពខ្វះខាត សុខភាពមិនល្អ ( ខ្សោយ ) ខ្ជិលរៀនសូត្រ ឪពុកម្ដាយមិនសូវយកចិត្តទុកដាក់ក្នុងការរៀន មិនបានធ្វើកិច្ចការជូនគ្រូ គ្រូស្ដីបន្ទោសច្រើន មាតាបិតាមិនយកចិត្តទុកដាក់ការរៀនសូត្ររបស់កូន ហើយប្រើជួយការងារផ្សេងៗ និងដោយសារកុមារខ្សោយពីថ្នាក់ក្រោមផង

- សង្គមរស់នៅពុំសូវល្អ ( សប្បូរល្បែង វីដេអូរ ) នាំអោយសិស្សខ្ជិល

- សេពគប់ចំពោះមិត្តដែលឪពុកម្តាយគេមិនអោយកុមារនោះមករៀន ( សិស្សមួយចំនួននោះក៏ចេះដើរលេងតាមទៅ )

- ផ្ទះឆ្ងាយពីសាលារៀន ធុញទ្រាន់ក្នុងការរៀនសូត្រ គ្រូខ្វះគរុកោសល្យក្នុងការអប់រំ និងការបង្រៀន

- មាតាបិតាសិស្សមិនទាន់យល់ពីតំលៃនៃការរៀនសូត្រ មាតាបិតារបស់សិស្សខ្វះក្រ ( ខ្វះមធ្យោបាយគំរូវតាមសេចក្តីត្រូវការរបស់សាលា )

- តំបន់រស់នៅខ្វះការអភិវឌ្ឍលើគ្រប់វិស័យ

- ជួនកាលមានសិស្សធំៗ ធ្វើបាបសិស្សតូចៗ ជាហេតុមួយបណ្តាលអោយសិស្សតូចៗ ខ្លាចមិនហ៊ានមកសាលារៀន សិស្សខ្វះធំពេកក៏មិនហ៊ានមកសាលារៀនដែរ ។

- នៅតាមមូលដ្ឋានមានល្បែងកំសាន្តច្រើននាំអោយក្មេងអត់ងងុយខកពេលរៀនសូត្រ ។

**ដើម្បីកែលំអ និងជួយជំរុញអោយបញ្ហាវត្តមានមានលក្ខណៈល្អប្រសើរ គ្រូត្រូវ ៖**

- ទទួលសិស្សអោយចូលរៀនគ្រប់អាយុ ធ្វើអោយសិស្សរីករាយក្នុងការរៀនសូត្រ សិស្សមានសុខភាពល្អគ្រប់គ្រាន់

- គ្រូមានគរុកោសល្យគ្រប់គ្រាន់ក្នុងការអប់រំសិស្ស ត្រូវមានទំនាក់ទំនងជាមួយមាតាបិតាសិស្ស និងសហគមន៍

- មានសំភារៈច្រើនក្នុងការបង្រៀន សិស្សមានសកម្មភាពក្នុងការប្រើប្រាស់សំភារៈ

- វិធីសាស្ត្រ និងល្បិចបង្រៀនមានការប៉ិនប្រសប់ គ្រូចុះជួបផ្ទាល់ជាមួយឪពុកម្តាយសិស្ស និងពន្យល់គាត់អោយយល់ពីតំលៃនៃការសិក្សា

- អោយសិស្សពូកែជួយបង្រៀនសិស្សខ្សោយបន្ថែម កិច្ចការក្នុងថ្នាក់គ្រូតាមដានពិនិត្យ និងកែលំអលើកទឹកចិត្តដោយផ្តល់រង្វាន់នៅដំណាច់ឆមាសនីមួយៗ និងដំណាច់ឆ្នាំសិក្សា

- មានទំនាក់ទំនងតាមរយៈលិខិត រឺចុះផ្ទាល់ដល់ផ្ទះ ដោយប្រាប់ឪពុកម្តាយកុំអោយកូនដើរលេងហួសហេតុពេកបណ្តាំផ្ញើនេះនាំអោយគាត់ជួយជំរុញកូនមករៀនបានទៀងទាត់

- គ្រូអប់រំសិស្សកុំអោយសេពគប់មិត្តអាក្រក់

- គ្រូត្រូវពង្រឹងវិន័យដល់សិស្សនៅក្នុងថ្នាក់ ស្រាវជ្រាវជីវភាពរស់នៅរបស់សិស្ស

- អប់រំសិស្សអោយបន្ថយការដើរកំសាន្តច្រើន និងអោយស្គាល់ផលប្រយោជន៍នៃការសិក្សា

- ព្យាយាមលើកទឹកចិត្តសិស្សខ្សោយដែលឧស្សាហ៍ឈប់អោយចូលចិត្តចង់រៀនឡើងវិញ

- អោយមាតាបិតាសិស្សជួយជំរុញកូនក្នុងការសិក្សា

- ត្រូវលើកទឹកចិត្តសិស្សដោយអោយមានសំភារៈសំបូរបែប ជីវភាពគ្រប់គ្រាន់ គ្រូមានទេពកោសល្យល្អ ។

## សំនួរ

២.ក). តើមូលហេតុ រឺ កត្តាអ្វីខ្លះ ដែលបានរាំងមិនអោយសិស្សរៀនចប់កម្មវិធីសិក្សា ?

ខ). តើគ្រូអាចដោះស្រាយបញ្ហាទាំងនេះបានដូចម្តេចខ្លះ ?

**សំគាល់** : លើចំលើយនៃសំនួរ ២.ក). និង ២.ខ). គ្រូបានគិតទាំងបញ្ហាដែលទាក់ទងទៅនឹងបញ្ហានៅក្នុងសាលារៀន និងតាមផ្ទះ ។

## ចំលើយ

**មូលហេតុដែលនាំអោយសិស្សរៀនមិនបានចប់កម្មវិធី ៖**

- សិស្សមានអវត្តមានច្រើននាំអោយខ្សោយ គ្រូអវត្តមានច្រើន
- មេរៀនដែលខ្លួនរៀនហួសសមត្ថភាព ( មិនយល់ ចាប់មិនបាន )
- រយៈពេលរៀនមេរៀននីមួយៗ ខ្លីពេក កម្មវិធីច្រើន
- អារម្មណ៍មិនសូវមូលដោយបញ្ហារស់នៅមានការខ្វះខាត ខ្វះសំភារៈសិក្សា
- បញ្ហាសិស្សធំហួសអាយុ មិនយល់ពីតំលៃការសិក្សា
- សិស្សរៀនខ្សោយ ឈប់ច្រើន មិត្តភក្តិអូសទាញ
- សិស្សមានជំងឺ សិស្សមិនគោរពវិន័យក្នុងសាលា រវល់ការងារឪពុកម្តាយ ជួយមើលប្អូន
- សិស្សភាគច្រើនខ្សោយក៏នាំអោយកម្មវិធីសិក្សារបស់គ្រូយឺតពេលដែរ ព្រោះគ្រូត្រូវប្រើពេលច្រើនដើម្បីបង្រៀនចំពោះសិស្សខ្សោយ
- ចំនួនសិស្សនៅក្នុងថ្នាក់ហួសការកំណត់ ( កំនែកិច្ចការរបស់សិស្សប្រើរយៈពេលយូរ )
- គ្រូរវល់ចូលរួមក្នុងពិធីបុណ្យប្រពៃណីជាតិ ប្រជុំច្រើន
- វិន័យសាលាតឹងតែងលើសសមត្ថភាពសិស្ស កម្មវិធីសិក្សាតាមមុខវិជ្ជាវែងពេក ពេលវេលាខ្លី
- ចំណេះដឹងមិនស្មើគ្នា គ្រូអវត្តមានច្រើន ។

**គ្រូបង្រៀនអាចដោះស្រាយបញ្ហាទាំងនោះបានដោយ ៖**

- សិស្សពូកែជួយបង្រៀនសិស្សខ្សោយ គ្រូជួយបន្ថែមប៉ិនក្រៅម៉ោង
- រៀបចំក្រុមសិស្សដែលនៅផ្ទះជិតៗ គ្នាបង្កើតជាក្លឹបសិក្សា
- សិស្សពូកែជួយសិស្សខ្សោយ ជួយប៉ិនតាមក្រុមតូចៗ
- គ្រូចេះសង្ខេបមេរៀនអោយខ្លី មេរៀនសមស្របតាមមូលដ្ឋាន
- សិស្សមានសៀវភៅគ្រប់មុខវិជ្ជាគ្រប់ៗ គ្នា ក្នុងម្នាក់មួយក្បាល ។

## សំនួរ

៣. តើយើងអាចលើកទឹកចិត្តប្រជារាស្ត្រអោយយកចិត្តទុកដាក់លើបញ្ហា ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍បានដូចម្ដេចខ្លះ ?

## ចំលើយ

យើងអាចលើកទឹកចិត្តប្រជារាស្ត្រអោយយកចិត្តទុកដាក់លើបញ្ហាទំនាក់ទំនងរវាងសាលារៀន និងសហគមន៍បានដោយ ៖

- ធ្វើការទំនាក់ទំនងជាមួយរដ្ឋអំណាច អាចារ្យវត្តអោយជួយដាស់តឿនមាតាបិតាសិស្សស្គាល់ពីតំលៃនៃការសិក្សារបស់កូន
- ត្រូវលើកទឹកចិត្តសិស្សពូកែ
- យើងត្រូវបំផុសប្រជារាស្ត្រអោយយល់តំលៃវិជ្ជា និងបំបាត់គ្រោះមិនចេះអក្សរ
- ត្រូវបំផុសមហាជនអោយធ្វើទំនាក់ទំនងជាមួយរដ្ឋអំណាច និងព្រះសង្ឃអោយជួយកសាងសាលារៀន និងជួយថែទាំសាលារៀន
- ត្រូវខិតខំបញ្ចេញអោយអស់សមត្ថភាពក្នុងការបង្រៀនសិស្សអោយបានល្អ ដើម្បីអោយសិស្ស និងមាតាបិតាសិស្សមានជំនឿលើសាលារៀន និងលើយើងដែលជាគ្រូបង្រៀន
- ត្រូវផ្ដល់ពត៌មានពីលទ្ធផលនៃការសិក្សារបស់សិស្សដល់មាតាបិតាសិស្ស លើកសរសើរ និងផ្ដល់រង្វាន់
- ធ្វើអោយមានភាពយុត្តិធម៌ទៅលើការរៀនសូត្ររបស់សិស្ស និងឧស្សាហ៍ផ្ដល់ពត៌មានដល់មាតាបិតា ។

**ក្រអ្វីក្រចុះ កុំអោយតែក្រគំនិត**

*

* *

# វិទ្យាសាស្ត្រអនុវត្ត

✻ ************

ការសិក្សាមុខវិជ្ជាណាមួយ លោកគ្រូ - អ្នកគ្រូ ត្រូវយល់ច្បាស់ពីគោលបំណងនៃមេរៀននោះជាមុនសិន ។ លោកគ្រូ - អ្នកគ្រូ ត្រូវសួរខ្លួនឯងរកអត្ថប្រយោជន៍នៃមេរៀន រួចហើយទើបរិះរកមធ្យោបាយ រឺ និយាយម្យ៉ាងទៀតថា វិធីសាស្ត្រសមស្របដើម្បីសំរេចគោលបំនង ។

ខាងក្រោមនេះ ជាគោលបំនងនៃការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្តនៅបឋមសិក្សា ។ យើងខ្ញុំសូមលោកគ្រូ - អ្នកគ្រូអានដោយយកចិត្តទុកដាក់ ដើម្បីរកអោយឃើញនូវគោលបំនងនៃការបង្រៀនវិទ្យាសាស្ត្រអនុវត្ត ដើម្បីនឹងប្រតិបត្តិតាម ។

គណៈកម្មាធិការកណ្តាល

************ ✻

## គោលបំនងនៃការបង្រៀន មុខវិជ្ជាវិទ្យាសាស្ត្រអនុវត្តនៅបឋមសិក្សា

វិទ្យាសាស្ត្រអនុវត្ត ជាមុខវិជ្ជាមួយយ៉ាងសំខាន់នៅបឋមសិក្សា ដែលមានគោលបំនងធ្វើអោយសិស្សទទួលបាននូវបទពិសោធន៍ផ្សេងៗ ដើម្បីអនុវត្តជាក់ស្តែងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ពិសេសគិតគូរដល់បញ្ហាសុខភាព និងបញ្ហាផ្ទាល់របស់គេ ។

ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្តនៅបឋមសិក្សា គឺធ្វើអោយសិស្សយល់ដឹងអំពីបរិដ្ឋាន សម្បត្តិធម្មជាតិ និងសុខភាព ។ ចេញពីការយល់ដឹងនេះ គេនឹងមានគំនិតថែរក្សា បរិដ្ឋានអោយបានល្អប្រឆាំងនឹងការធ្វើអោយមានកង្វក់បរិយាកាស កង្វក់ទឹក ប្រឆាំងនឹងការបំផ្លាញសម្បត្តិធម្មជាតិ ជាពិសេសព្រៃឈើ ដែលមានឥទ្ធិពលល្អចំពោះបរិដ្ឋាន ត្បូងថ្មមានតំលៃ សត្វព្រៃ និងត្រីក្នុងបឹងទន្លេសាបជាសំខាន់ ។

វិទ្យាសាស្ត្រអនុវត្តក៏មានគោលបំនងអប់រំសិស្សអោយជឿជាក់លើវិទ្យាសាស្ត្រ បំបាត់ជំនឿអរូបីពុំសមហេតុផល ស្រឡាញ់ធម្មជាតិ ។ មុខវិជ្ជានេះមានលក្ខណៈផ្សារភ្ជាប់ទ្រឹស្តី និងការប្រតិបត្តិ សាលារៀន និងសង្គមគ្រួសារ អ្នកវិទ្យាសាស្ត្រ និងអ្នកបច្ចេកទេស ។

មុខវិជ្ជានេះក៏បានរួមចំណែកបណ្តុះបណ្តាលប្រជាពលរដ្ឋល្អប្រសើរនៅថ្ងៃអនាគតដែរ ។

ដើម្បីអោយសិស្ស ចូលចិត្ត និងយកចិត្តទុកដាក់ក្នុងការសិក្សាមុខវិជ្ជានេះ គ្រូគួរខិតខំរកវិធីទាក់ទាញសិស្សអោយជក់ចិត្តក្នុងការសិក្សា ពោលគឺលើកសំនួរផ្ទាល់មាត់សាមញ្ញៗ ក្នុងភាពស្និទ្ធស្នាលអោយបានច្រើន អោយសិស្សឆ្លើយ និងប្រើឧបករណ៍ពិសោធសាមញ្ញាដែលសិស្សងាយរក ដើម្បីធ្វើពិសោធន៍ក្នុងថ្នាក់ និងអាចពិសោធនៅផ្ទះបាន ។ គ្រូត្រូវជៀសវាងការអោយសិស្សទន្ទេញមេរៀនចាំមាត់តែមួយភ្លែត ហើយភ្លេចទៅវិញនោះ ។

ម្យ៉ាងទៀត មេរៀនវិទ្យាសាស្ត្រអនុវត្តនៅបឋមសិក្សាទាមទារអោយសិស្សគូររូបតំណាងផ្សេងៗ តាមខ្លឹមសារមេរៀន ដូចជាប្រដាប់រំលាយអាហារ ប្រដាប់ដកដង្ហើម ។ ទស្សនកិច្ចក្រៅថ្នាក់ក៏ជាសកម្មភាពសំខាន់មួយរបស់សិស្សក្នុងការសិក្សាមេរៀនវិទ្យាសាស្ត្រអនុវត្តដែរ ។

ដោយលោក **យ៉ីង់ យ៉ាណូ**

**កើតជាអង្គ ពង្សជាមនុស្ស ប្រុស រឺ ស្រី**
**មានសំដី ថ្វីគំនិត គិតគ្រប់ប្រាណ**
**ត្រូវប្រឹងរៀន រៀនអោយចេះ ចេះចំណាន**
**ទើបជាតិបាន ថានខ្ពង់ខ្ពស់ យសថ្កើងថ្កាន**

# « គ្មានទេ ថ្នាក់ស្មើសាច់នោះ »

ការរៀបចំគរុកោសល្យដែលសមហេតុផលត្រូវ អោយរៀបចំថ្នាក់រៀនអោយបានស្មើសាច់ ពោលគឺកំរិតបញ្ញាសិស្សអោយស្មើៗ គ្នា ។ គ្រូចង់បានណាស់នូវស្ថានភាពថ្នាក់បែបនេះ ប៉ុន្តែក្នុងជីវភាព សាលារៀនជាក់ស្តែងគេកំរ ជួបប្រទះណាស់នូវថ្នាក់ស្មើសាច់នោះ ។ ជាធម្មតាថ្នាក់នីមួយៗ មានក្រុមសិស្សពូកែ ក្រុមសិស្សមធ្យម និងក្រុមសិស្សខ្សោយ ពោលគឺគេកំររកបានណាស់នូវថ្នាក់ដែលសិស្សទាំងអស់មានកំរិតបញ្ញា និងកំរិតសម្បទាស្មើគ្នា ។ បើស្ថានភាពថ្នាក់បែបនេះ គ្រូត្រូវដឹកនាំថ្នាក់យ៉ាងណា ? ចំពោះសិស្សខ្សោយ ត្រូវធ្វើដូចម្តេច ? ចំពោះសិស្សពូកែត្រូវធ្វើដូចម្តេច ?

## ១- សិស្សខ្សោយបង្ខំគ្រូអោយរំលឹកមេរៀនចាស់ជាញឹកញយ

ជាទូទៅ សិស្សខ្សោយមិនមែនសុទ្ធតែយឺតយ៉ាវ រឺ ល្ងីល្ងើនោះទេ ក៏ប៉ុន្តែជាកុមារមិនចូលចិត្តធ្វើការងារ រឺក៏មានជំងឺ ។ សិស្សប្រភេទនេះ ក្រយល់ជាងសិស្សពូកែ ។ ប្រការនេះទាមទារអោយគ្រូយកចិត្តទុកដាក់ លើប្រសិទ្ធិភាពនៃមេរៀនរបស់គាត់ ទាមទារអោយរំលឹកមេរៀនចាស់ជាប្រចាំ ។ ស្ថានភាពសិស្សខ្សោយបង្ហាញអោយគ្រូដឹងថា ការបង្រៀនរបស់គ្រូត្រូវចាប់ដំនើរពីសិស្សមធ្យមទៅមិនមែនចេញពីសិស្សពូកែនោះទេ ។ ការសាឡើងវិញ ជាព្រលឹងនៃការបង្រៀន និងជាគោលការណ៍ ជាមូលដ្ឋានរបស់សាលារៀនបឋមសិក្សា ។ អោយសិស្សចេះតិចចុះ ប៉ុន្តែចេះល្អ មានអនុស្សាវរីយ៍តិចចុះ ប៉ុន្តែជាអនុស្សាវរីយ៍មានលំដាប់ ។ ការសាឡើងវិញបានធ្វើអោយរស់អនុស្សាវរីយ៍ចាស់ៗ ។ នវគ្រូ[(១)] ភាគច្រើនមានទំនោរយកចិត្តទុកដាក់ទៅលើសិស្សពូកែ ហើយបំភ្លេចសិស្សខ្សោយ ។ នេះគឺជាប្រការឆ្គាំឆ្គង ។ គ្រូបង្រៀនត្រូវតែចងចាំថា : គ្រូបង្រៀនជាគ្រូរបស់សិស្សទាំងអស់ក្នុងមួយថ្នាក់មិនមែនជាគ្រូរបស់សិស្សពូកែ តែបួន រឺ ប្រាំនាក់ទេ ។ គេវាយតំលៃការងាររបស់គាត់ទៅលើលទ្ធផលសិក្សារបស់គាត់ទូទាំងថ្នាក់ មិនមែនទៅលើតែសិស្សពូកែប៉ុន្មាននាក់នោះទេ ។

## ២- សិស្សពូកែសំរាប់ជាជីវចលករ និងបង្កើតការប្រលងប្រណាំង

សិស្សពូកែមានប្រាជ្ញាទូលំទូលាយ ឆាប់យល់ រាល់គ្រប់មេរៀន ។ សិស្សប្រភេទនេះយើងមិនត្រូវបន្ទន់បង្អាក់ទេ តែផ្ទុយទៅវិញគ្រូត្រូវត្រៀមសំនួរបន្ថែម លំហាត់បន្ថែម ដើម្បីជាកិច្ចលើកទឹកចិត្ត ។ សិស្សប្រភេទនេះជាអ្នកទាក់ទាញសិស្សខ្សោយ និងបង្កើតការប្រលងប្រណាំងដែលដឹកនាំដោយគ្រូមានយុត្តិធម៌ ។ ការប្រលងប្រណាំង គឺជាមនោសញ្ចេតនាដែលចង់រៀនអោយពូកែជាងមិត្តរួមថ្នាក់ ។ ចំណាត់ថ្នាក់អាចក្លាយទៅជាមានគ្រោះថ្នាក់ កាលណាគេញែកដាច់ អ្នកដែលគេយកចិត្តទុកដាក់ និងអ្នកដែលគេត្រូវបោះបង់ចោល ។ ត្រូវជៀសវាងជាដាច់ខាត នូវការលើកអ្នកពូកែអោយខ្ពស់ពេកដើម្បីធ្វើអោយអ្នកខ្សោយខកចិត្តពេក ។ ការប្រលងប្រណាំងដែលល្អគឺផ្តល់រង្វាន់ ដល់ការប្រឹងប្រែងរបស់អ្នកខ្លះ និងដល់ជោគជ័យរបស់អ្នកខ្លះទៀត ។

ជាទូទៅថ្នាក់នីមួយៗ តែងតែមានសិស្ស ពូកែ និង សិស្សខ្សោយ គឺជាជំងឺគរុកោសល្យចាំបាច់មួយខាងមិនបាន ដែលទាមទារអោយគ្រូចេះផ្សារភ្ជាប់ការបង្រៀនរបស់ខ្លួនជាមួយសិស្សពូកែ និង សិស្សខ្សោយ ។ មាតាបិតាតែងមានព្រហ្មវិហារធម៌ ចំពោះគ្រប់កូនៗ ជាពិសេសកូនទុរគត និងពិការយ៉ាងណា គ្រូបង្រៀន ក៏ត្រូវមានព្រហ្មវិហារធម៌ ចំពោះសិស្សទាំងអស់ ពិសេសសិស្សខ្សោយក៏យ៉ាងនោះដែរ ។ គ្រូត្រូវដឹកនាំការបង្រៀនរបស់ខ្លួន សំរាប់ថ្នាក់ទាំងមូលផង និងសំរាប់សិស្សម្នាក់ៗ ផង ។ ដំបូន្មានគរុកោសល្យមួយឃ្លាបានបំភ្លឺផ្លូវគ្រូបង្រៀនយើងជានិច្ចជាកាលថា : ‹‹ ជំរុញសិស្សខ្សោយដោយមិនពន្យឺតសិស្សពូកែនេះ ហើយជាសិល្បៈរបស់គ្រូបង្រៀន ›› ។

ដោយលោក **ឆឹម សុត**

(១) - នវគ្រូ : គ្រូថ្មី